# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍ឆ្នាំ២០១៨
# ស្តីពី
# កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច



**រៀបចំដោយៈ**

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
នៃលេខាធិការដ្ឋាន គ.ជ.អ.ប
ខែធ្នូ ឆ្នាំ២០១៨

# មាតិកា

**១. សេចក្តីផ្តើម**..........១
**២. សកម្មភាព និងលទ្ធផលសម្រេចបាន**..........១
២.១.ការរៀបចំបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៨..........២
២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ..........២
២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក..........៣
២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត..........៤
២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង..........៥
២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់..........៥
២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក..........៥
២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត..........៦
២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាជីផ្លីគម្រោងឆ្នាំ២០១៧ក្រោយពេលដេញថ្លៃ..........៦
២.៤. ការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ..........៨
២.៥. ការពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ..........៩
២.៦.ការគាំទ្រ និងកិច្ចសហការនៅថ្នាក់ជាតិ..........១៥
**៣. បញ្ហាប្រឈមនានា**..........១៨
**៤. ការសន្និដ្ឋាន**..........១៩
**៥. អនុសាសន៍ និងសំណូមពរ**..........២០
**៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៩**..........២១
**ឧបសម្ព័ន្ធ**
១.តារាងតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពគម្រោងឆ្នាំ២០១៨ និងការផ្តល់យោបល់បច្ចេកទេស
២. បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ជីផ្លី និងជនជាតិដើមភាគតិច

## ១. សេចក្តីផ្តើម

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច គឺជាយន្តការមួយសម្រាប់ប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។ យន្តការមួយនេះ ត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងបីប្រភេទ ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្នជាមុនលើផលប៉ះពាល់ និងហានិភ័យលើបរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោង។ គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច គឺដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមា ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់លើបរិស្ថាន ឬចំណាយសង្គមចំពោះក្រុមជនងាយរងគ្រោះ ហើយដែលអាចទទួលរងឥទ្ធិពលពីការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់ សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិទៅឱ្យគម្រោង ការធ្វើសំណង និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគ។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០១៨នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានអនុវត្តន៍តាមផែនការសកម្មភាព និងថវិកាដែលបានលើកឡើង ហើយសម្រេចបានលទ្ធផលជារួមនូវចំណុចគោលដូចខាងក្រោម៖

- ធ្វើការទំនាក់ទំនងជាមួយទីចាត់ការផែនការ និងវិនិយោគខេត្ត ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដើម្បីងាយស្រួលផ្ទៀងផ្ទាត់ មុនដេញថ្លៃគម្រោង
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងនៅក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិច
- ចុះតាមដាននិងត្រួតពិនិត្យការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីរបស់គម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក នៅតាមខេត្តដែលបានកំណត់
- ចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញនិងសិក្ខាសាលាស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងជាច់ដោយឡែករបស់លេខាធិការដ្ឋាន គ.ជ.អ.ប មានដូចជា គម្រោងSRL គម្រោងDDRR និងគម្រោងPBCR នៅតាមខេត្ត និងស្រុកគោលដៅ
- ចុះវាយតម្លៃគម្រោងSRL និងស្រង់ទិន្នន័យដើមគ្រាឆ្នាំ២០១៨ ដើម្បីវាយតម្លៃជំហានមួយសម្រាប់ថ្នាក់ក្រោមជាតិទទួលមូលនិធិបន្ថែមរបស់គម្រោងឆ្នាំ២០១៩របស់គម្រោង PBCR

- រៀបចំ និងកែសម្រួលគោលការណ៍ណែនាំស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទៅជាគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ចូលរួមធ្វើបទបង្ហាញស្តីពីការបញ្ចូលទិន្នន័យគម្រោងក្នុងប្រព័ន្ធភីដ(PID)លើការពិនិត្យឯកសារគម្រោងផ្នែកបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីជំនួយបច្ចេកទេសនៅថ្នាក់ក្រោមជាតិដែលរៀបចំឡើងនៅក្នុងខេត្តក្រចេះ។

## ២.១.ការរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងខេត្ត ឆ្នាំ២០១៨ ៖

### ២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ៖

គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅដើមឆ្នាំ២០១៨ សរុបមានចំនួន១៦៨៤គម្រោងនៃ១៥៣៧ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបមានចំនួន ៦៨៩គម្រោង តម្រូវការសិក្សាដីធ្លីសរុបមានចំនួន៣៦៥គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបមានចំនួន៥៨គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិត នៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន៦៦៧គម្រោង និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច សរុបមានចំនួន៥៨គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤។ ខេត្តដែលមិនបានផ្ញើបញ្ជីគម្រោង និងឯកសាររបាយការណ៍វិភាគបរិស្ថាន និងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមកលេខាធិការដ្ឋានដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគឺ ខេត្តព្រៃវែង ខេត្តកណ្តាល និងខេត្តឧត្តរមានជ័យ។

រូបភាពទី១៖ ក្រាហ្វិចចំនួនឃុំសង្កាត់ និងចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាពស្នើឡើងដើមឆ្នាំ




ជាក់ស្តែងគម្រោងដែលខេត្តបានអនុវត្តសរុបចំនួន១៥១៥គម្រោង ក្នុងនេះមានផ្លូវជីស ផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលក្រួសធម្មជាតិ និងផ្លូវបេតុងអាមេរ៉េសរុបចំនួន១២៦០គម្រោង ស្ពានឈើ និងស្ពានបេតុងចំនួន២៣គម្រោង ប្រឡាយដីក និងទំនប់ចំនួន១២៦គម្រោង ស្រះដីកនិងអណ្តូងស្នប់ចំនួន១៦

គម្រោង អគាររដ្ឋបាលសាលាឃុំ សាលារៀន សាលារៀនបណ្តែតទឹក សាលាមេតយ្យ និងមណ្ឌលសុខភាព ចំនួន២១គម្រោង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក លូបង្ហៀរ ប្រព័ន្ធទុយយោទឹក កែលម្អសួនច្បារ អនាម័យបរិស្ថានចំនួន៤៤គម្រោង។ ក្រាហ្វិចខាងក្រោម បង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

**រូបភាពទី២៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងឃុំ សង្កាត់ ឆ្នាំ២០១៨**




## ២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ៖

គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៨ មានចំនួនសរុប២៦៧ គម្រោងនៃ ១៥៤ក្រុង ស្រុក នៅក្នុង១៥ខេត្ត។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន១៤០គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន១៩គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន៤៨គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន១៤២គម្រោង និងនៅក្នុងតំបន់ជនជាតិដើមភាគតិចចំនួន៤៨គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងដើមឆ្នាំ ។

**រូបភាពទី៣៖ ក្រាហ្វិចចំនួនក្រុង ស្រុក និងតម្រូវការសិក្សាសុវត្ថិភាព**



នៅក្នុងគម្រោងសរុបចំនួន២៦៧នេះ មានផ្លូវក្រាលក្រួសក្រហម ផ្លូវបេតុងអាមេរ៍ និងផ្លូវក្រាលក្រួសធម្មជាតិចំនួន៧៩គម្រោង ជួសជុលអគាររដ្ឋបាលសាលាស្រុកចំនួន៤គម្រោង និងផ្សេងៗដែលមានដូចជាប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក កែលម្អសួនច្បារ ជួសជុលរបងអាគារ ជួសជុលដំបូលសាលាស្រុក កែលម្អខ្លោងទ្វារសាលាស្រុក ចាក់សាបទីធ្លាសាធារណៈ តម្លើងបង្គោលភ្លើងបំពាក់សូឡាសរុបចំនួន២៦គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

**រូបភាពទី៤៖ ក្រាហ្វិចឈ្មោះគម្រោងក្រុង ស្រុក និងចំនួនគម្រោង**




### ២.១.៣.បញ្ជីគម្រោងមូលនិធិខេត្ត ៖

មានតែខេត្តកែប និងខេត្តប៉ៃលិន ដែលបានអនុវត្តគម្រោងខេត្តបានចំនួន១៥គម្រោង ក្នុងនេះតម្រូវការសិក្សាបរិស្ថានមានចំនួន១៥គម្រោង មិនមានតម្រូវការសិក្សាដីធ្លីនិងសិក្សាជនជាតិដើមភាគតិចទេ។ ខេត្តផ្សេងៗទៀតមិនបានផ្ញើបញ្ជីគម្រោង និងឯកសាររបាយការណ៍របស់គម្រោងមកក្រុមការងារនៃលេខាធិការដ្ឋានឡើយ។ នៅក្នុង១៥គម្រោងនេះ មានផ្លូវកៅស៊ូ DBST ផ្លូវបេតុងអាមេរ៍ ផ្លូវក្រួសក្រហមចំនួន៩គម្រោង សាងសង់អគារច្រកចេញចូលតែមួយ ព្រមទាំងផ្សេងៗដែលមានដូចជាជួសជុលចាក់ដីច្រាំងសមុទ្រ និងប្រព័ន្ធលូដោះទឹកចំនួន៦គម្រោង។

**រូបភាពទី៦៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងរបស់ខេត្តកំពត និងប៉ៃលិន**



## ២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង៖

### ២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប៤១៧គម្រោងស្មើនឹង៦៣%នៃចំនួនសរុប៦៦៧គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន៤៤គម្រោង ស្មើនឹង ៧៥% នៃចំនួន៥៩គម្រោង ដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។ ក្នុងនេះ មានគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានដែលហៅកាត់ថា ASPIRE ភ្ជាប់ជាមួយគម្រោងឃុំ សង្កាត់ផងដែរ។

រូបភាពទី៧៖ ក្រាហ្វិចចំនួនគម្រោងឃុំ សង្កាត់ និងភាគរយដែលបានពិនិត្យនិងផ្តល់យោបល់បច្ចេកទេស




### ២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប៩៣គម្រោងស្មើនឹង៦៥%នៃ១៤២គម្រោងនិងរបាយការណ៍ការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន៤៨គម្រោងនៃ៥៩គម្រោងស្មើនិង៧៥%។

រូបភាពទី៨៖ ក្រាហ្វិចចំនួនគម្រោងក្រុង ស្រុក និងភាគរយដែលបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេស



### ២.២.៣.ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្តៈ

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្តកែប និងខេត្តប៉ៃលិនលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួន១៥គម្រោងនៃគម្រោងសរុបចំនួន១៥ស្មើនឹង១០០% និងមិនមានគម្រោងទាក់ទងទៅនឹងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចទេ។

រូបភាពទី៩៖ ក្រាហ្វិចចំនួនគម្រោងខេត្ត និងភាគរយដែលបានពិនិត្យ




### ២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៧ ៖

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគខេត្តរតនគិរី ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្រុមការងារបានពិនិត្យគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៧របស់ខេត្តរតនគិរី ក្នុងនោះគម្រោងស្នើឡើងសរុបចំនួន៤៨គម្រោង តម្រូវការសិក្សាបរិស្ថានមានចំនួន៣៩គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន១៥គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមាន៣៨គម្រោង។ ក្នុងគម្រោងសរុបចំនួន៤៨នេះ បានចុះកិច្ចសន្យា និងអនុវត្តន៍បាន១០០%ទាំងអស់។ គម្រោងដែលបានត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីសរុបចំនួន១៥គម្រោងស្មើនឹង១០០%នៃគម្រោងសិក្សាដីធ្លីទាំងអស់។

នៅថ្ងៃទី២២ និង២៣ ខែសីហា ឆ្នាំ២០១៨ៈក្រុមការងារបានចុះទៅតាមឃុំដែលបានជ្រើសរើសចំនួន៤ ក្នុងស្រុកចំនួន២ សរុបរួចំនួន៤២នាក់ស្ត្រី៨នាក់ ឃុំទាំងបួនមានដូចខាងក្រោមៈ

ក).ចុះទៅឃុំតឺន ស្រុកកូនមុំ ដោយមានការចូលរួមពីអភិបាលរងស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងមេភូមិសរុបចំនួន១០នាក់ ស្ត្រីចំនួន១នាក់(ក្រុមការងារថ្នាក់ជាតិមានចំនួន២រូបស្ត្រីចំនួន១នាក់)។ ក្រុមការងារបានចុះទៅពិនិត្យដល់ទីតាំងគម្រោងសាងសង់ផ្លូវក្រួសក្រហមប្រវែង១៣០០ម៉ែត្រ ដាក់លូ៣កន្លែង និងស្លាកសញ្ញាគម្រោង១កន្លែង។ គម្រោងអនុវត្តន៍បាន១០០%។

ខ).ចុះទៅឃុំត្រពាំងច្រេស ស្រុកកូនមុំ ដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់ មេឃុំ ជំទប់ទី១ ជំទប់ទី២ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ប្រធានភូមិសរុបចំនួន១២នាក់ស្ត្រីចំនួន៤នាក់(ក្រុមការងារថ្នាក់ជាតិមាន២នាក់ស្ត្រី១នាក់)។ ក្រុមការងារបានចុះទៅពិនិត្យដល់ទីតាំងគម្រោងជួសជុលផ្លូវក្រួសក្រហមប្រវែង១៦៥០ម៉ែត្រ និងដាក់លូ២កន្លែង។ គម្រោងអនុវត្តន៍បាន១០០%។



ក្រុមការងារកិច្ចការពារសុវត្ថិភាព ប.ដ.ជ ពិនិត្យឯកសាររបាយការណ៍ដីធ្លីនៅទីចាត់ការផែនការ និងវិនិយោគខេត្តរតនគិរី

គ).ចុះទៅឃុំលំជ័រ ស្រុកអូរយ៉ាដាវ ដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំសង្កាត់ មេឃុំ ជំទប់ទី២ ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ សរុបចំនួន៩នាក់ស្ត្រីចំនួន១នាក់(ក្រុមការងារថ្នាក់ជាតិមាន២នាក់)។ ក្រុមការងារបានចុះទៅពិនិត្យដល់ទីតាំងគម្រោងសាងសង់ផ្លូវក្រាលក្រួសធម្មជាតិប្រវែង១,៤៥គីឡូម៉ែត្រ និងស្លាកសញ្ញាគម្រោង១កន្លែង។ គម្រោងអនុវត្តន៍បាន១០០%។

ឃ).ចុះទៅឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសខេត្ត មេឃុំ ជំទប់ទី២ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការឃុំ និងមេភូមិសរុបចំនួន១១នាក់(ក្រុមការងារថ្នាក់ជាតិមាន២នាក់)។ ក្រុមការងារបានចុះទៅពិនិត្យដល់ទីតាំងគម្រោងសាងសង់ផ្លូវក្រួសក្រហមប្រវែង១៤៥០ម៉ែត្រ ដាក់លូ១កន្លែង និងស្លាកសញ្ញាគម្រោង១កន្លែង។គម្រោងអនុវត្តន៍បាន១០០%។

ក្នុងអំឡុងពេលចុះទៅឃុំទាំងបួន ក្រុមការងារបានស្វាបស្ទង់ចំណេះដឹងក្រុមប្រឹក្សាឃុំ និងស្មៀនឃុំលើការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីតាមនីតិវិធីក្នុងសៀវភៅ(ភីម)បានពិនិត្យឯកសារច្បាប់ដើមរបស់គម្រោង បានបង្ហាញអំពីចំណុចខ្វះខាតក្នុងការបំពេញឯកសារ និងការអនុវត្តការសិក្សាវាស់វែងដីធ្លីដែលមានផលប៉ះពាល់ ការទំនាក់ទំនងទៅក្រុមប្រឹក្សាឃុំ និងបានរំលឹកឡើងវិញដល់ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំអំពីដំណើរការនៃការសិក្សាដីធ្លី និងការរៀបចំឯកសាររបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តឱ្យគម្រោងរួមទាំងនីតិវិធីនៃការអនុវត្តការវិភាគបរិស្ថាន និងកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិចដល់ពួកគាត់។

- **បញ្ហា**
  - ពិបាកអញ្ជើញប្រជាពលរដ្ឋជាម្ចាស់ក្បាលដីចូលរួមប្រជុំព្រមព្រៀងធ្វើឱ្យមានការពន្យាពេលយូរក្នុងការសិក្សាគម្រោង។
  - ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចមិនបានចូលរួមថែរក្សាផ្លូវឱ្យបានល្អ ដោយសារតែពួកគាត់ដាក់កំណាត់ឈើរាំងស្ទះទឹកហូរតាមស្នាផ្លូវ ធ្វើឱ្យមានទឹកភ្លៀងហូរច្រោះដើងទេរផ្លូវមានដក់ទឹកកើតជាភក់ជ្រាំ និងមានក្លិនមិនល្អនៅក្នុងភូមិ ដែលអាចកើតមានឡើងនូវជម្ងឺដម្កាត់ផ្សេងៗ។
- **ដំណោះស្រាយ**

• ក្រុមការងារបានជម្រាបជូនមេឃុំ មេភូមិ និងតំណាងប្រជាពលរដ្ឋដែលក្នុងបរិវេណផ្ទះមានបរិស្ថានមិនស្អាតដូចខាងលើត្រូវធ្វើការកែលម្អឡើងវិញដោយត្រូវយកចេញនូវកំណាត់ឈើមួយចំនួនដែលទប់ស្ទះចរន្តទឹកហូរ និងត្រូវសម្អាតភូមិដ្ឋានឱ្យបានស្អាត។

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨៖ក្រុមការងារបេសកកម្មបានជួបប្រជុំជាមួយអ្នកពាក់ព័ន្ធ នៅសាលប្រជុំរបស់សាលាខេត្តរតនគិរី ដើម្បីធ្វើបទបង្ហាញឆ្លុះបញ្ចាំងពីបេកគំហើញនៃការត្រួតពិនិត្យឯកសាររបាយការណ៍ និងការចុះត្រួតពិនិត្យការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីដល់ទីតាំងគម្រោង។ កិច្ចប្រជុំឆ្លុះបញ្ចាំងនេះ មានការចូលរួមពីនាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ប្រធាន អនុប្រធាន និងមន្ត្រីការិយាល័យផែនការគាំទ្រឃុំសង្កាត់ មន្ត្រីបច្ចេកទេសខេត្តសរុបចំនួន១៣នាក់ ស្ត្រីចំនួន២នាក់(ក្រុមការងារថ្នាក់ជាតិមាន៤នាក់ស្ត្រីចំនួន១នាក់)។

លទ្ធផលជារួម សង្កេតឃើញថា ការបំពេញឯកសារ និងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីគម្រោងឃុំសង្កាត់ឆ្នាំ២០១៧របស់ខេត្តរតនគិរីបានបំពេញត្រឹមត្រូវច្រើនក្នុងកម្រិតល្អបង្គួរ។



សកម្មភាពក្រុមការងារចុះត្រួតពិនិត្យកិច្ចការពារសុវត្ថិភាពដីធ្លីគម្រោងផ្លូវដីក្រាលក្រួសក្រហមនៅក្នុងឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី

## ២.៤. ការពង្រឹងសមត្ថភាពការងារនៅថ្នាក់ជាតិ ៖

o កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមក្នុងសិក្ខាសាលាស្តីពីការពង្រឹងការអនុវត្តកិច្ចការពារហានិភ័យបរិស្ថាន និងសង្គមនៅកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងរាជធានីភ្នំពេញ ដែលរៀបចំដោយក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៃធនាគារពិភពលោក (The World Bank) មានអ្នកចូលរួមមកពីស្ថាប័នក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក ក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.អ.ប សរុបចំនួន៥០នាក់។ នៅក្នុងសិក្ខាសាលានេះ មានបទបង្ហាញចំនួនពីរបេប្រធានបទគឺ៖ ទី១) ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម(E&S)នៅកម្ពុជា ទី២)ការឈានទៅកែលម្អការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងវិនិយោគ

នានានៅកម្ពុជា។ គម្រោងដែលត្រូវបានបញ្ចូលទៅក្នុងពិនិត្យឡើងវិញ គឺជាគម្រោងដែលទទួលបានមូលនិធិរបស់ធនាគារពិភពលោក(WB)។

## ២.៥. ការពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ៖

០បានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយអំពីការបំពេញទម្រង់ទាក់ទងទៅនឹងការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់សៀវភៅភីមថ្មី ដល់មន្ត្រី និងទីប្រឹក្សាអនុវត្តន៍គម្រោងSRL ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប សម្រាប់សិក្សាតម្រូវការកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង និងបំពេញទម្រង់គម្រោងឱ្យបានត្រឹមត្រូវ។

០ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៨ បានចូលរួមគាំទ្រសកម្មភាពសម្រាំងជ្រើសរើសសអ្នកទទួលផលរបស់គម្រោង SRL នៅក្នុងស្រុកគោលដៅទាំងដប់នៃខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន៧១២នាក់ស្រី៥៩៦នាក់។

០ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨នៅខេត្តកំពង់ធំ បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេត និងការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm ។ កិច្ចប្រជុំនេះមានអ្នកចូលរួម ៣៦ នាក់ស្រី១៧នាក់ ដែលជានាយករងរដ្ឋបាលសាលាខេត្ត ជានាយក និងជាមន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត ជានាយករដ្ឋបាល និងជាប្រធានការិយាល័យគាំទ្រឃុំ សង្កាត់នៃស្រុកសន្ទុក ស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកសណ្ដាន់ និងស្រុកប្រាសាទបល្ល័ង្ក ក្រុមការងារក្រុមហ៊ុន GIS Firm ទីប្រឹក្សាតំណាង UNDP ក្រុមការងារប្រឹក្សាអគ្គលេខាធិការដ្ឋានអភិវឌ្ឍន៍ដោយចីរភាព និងក្រុមការងារគម្រោង SRL ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

០ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ខេត្តសៀមរាប បានចូលរួមរៀបចំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេត ការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេតការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm សម្រាប់ជាគោលយកជាគោលធ្វើការវាយតម្លៃគម្រោង។ កិច្ចប្រជុំនេះមានអ្នកចូលរួម៣៨នាក់ស្រី១៥នាក់ ដែលមានសមាសភាពនាយករងរដ្ឋបាលសាលាខេត្ត នាយក និងមន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត នាយករដ្ឋបាល និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ថ្នាក់ស្រុកដែលមកពីស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកប្រាសាទបាគង ស្រុកក្រឡាញ់ ស្រុកវ៉ារិន ទីប្រឹក្សាតំណាង UNDP និងក្រុមការងារគម្រោងSRL ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

០ថ្ងៃទី២៦-២៧ ខែមេសា ឆ្នាំ២០១៨ បានចូលរួមសម្របសម្រួលនិងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹង

អាកាសធាតុនៅខេត្តបាត់ដំបង លើប្រធានបទកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងឃុំ សង្កាត់ ដល់មន្ត្រីអនុវត្តគម្រោងក្នុងស្រុកគោលដៅដែលមកពី១២ខេត្តមានអ្នកចូលរួមសរុបចំនួន២៤នាក់ ដែលមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត។

០ថ្ងៃទី៨-៩ ខែឧសភា ឆ្នាំ២០១៨ បានចូលរួមធ្វើបទបង្ហាញ និងសម្របសម្រួលក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពី"ការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ" ដែលផ្តោតលើប្រធានបទចំនួនពីរគឺទី១)."ការអនុវត្តមូលនិធិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ(PBCR Grant)" និងទី២)."ការចាត់ថ្នាក់មុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម" ក្នុងគម្រោង SRL នៅខេត្តកំពង់ចាម ដែលមានមន្ត្រី និងទីប្រឹក្សាចូលរួមសរុបចំនួន៤០នាក់ស្ត្រី៨នាក់មកពីស្រុកគោលដៅចំនួន១០របស់ខេត្តកំពង់ធំ និង ខេត្តសៀមរាប។

០ថ្ងៃទី៩-១០ ខែឧសភា ឆ្នាំ២០១៨ បានចូលរួមសម្របសម្រួល និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការ"រៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ" នៅខេត្តព្រៃវែង លើប្រធានបទ "កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងឃុំ សង្កាត់" ក្នុងសៀវភៅគឹមកែសម្រួលថ្មី និងប្រកាសឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០១៨ ដែលមានសិក្ខាកាមមកពីស្រុកគោលដៅទាំងដប់របស់ខេត្តព្រៃវែង និងមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត សរុបចំនួន៤០នាក់ស្ត្រី៦នាក់ ។

០ថ្ងៃទី៦-៧ ខែមិថុនា ឆ្នាំ២០១៨ បានចូលរួមធ្វើបទបង្ហាញផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងសៀវភៅគឹមឃុំ សង្កាត់ថ្មី នៅខេត្តសៀមរាប ដែលមានសិក្ខាកាមជាមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្តមកពីខេត្តចំនួន៨គឺ ខេត្តកំពត, ខេត្តកំពង់ចាម,ខេត្តក្រចេះ, ខេត្តព្រះវិហារ, ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តព្រៃវែង, និង ខេត្តស្វាយរៀង មានស្រុកគោលដៅចំនួន២៤ និងមានអ្នកចូលរួមសរុបចំនួន៧៥នាក់ស្រី១១នាក់។

០ថ្ងៃទី២-៦ ខែកក្កដា ២០១៨ បានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិចក្នុងសៀវភៅគឹមថ្មីសម្រាប់អនុវត្តក្នុងគម្រោង (PBCR Grant) សម្រាប់ ខេត្តព្រៃវែង និងខេត្តបាត់ដំបង។ នៅខេត្តព្រៃវែង វគ្គផ្សព្វផ្សាយចែកចេញជាពីរវគ្គដែលមាន វគ្គទី១រៀបចំសម្រាប់មន្ត្រីថ្នាក់ខេត្តមានសិក្ខាកាមចូលរួមសរុប៤១នាក់ស្ត្រី៨នាក់ វគ្គទី២រៀបចំសម្រាប់ថ្នាក់ស្រុកមានសិក្ខាកាមចូលរួមសរុបមានចំនួន៧៥នាក់ស្ត្រី២២នាក់ សរុបរួមមាន ចំនួន១១៦នាក់ស្ត្រី៣០នាក់។ នៅខេត្តបាត់ដំបង វគ្គទី១សម្រាប់ថ្នាក់ខេត្តមានសិក្ខាកាមចូលរួមសរុប៥៥នាក់ស្ត្រី១៤នាក់វគ្គទី២សម្រាប់មន្ត្រីថ្នាក់ស្រុកមានសិក្ខាកាមចូលរួមសរុប៥២នាក់ស្ត្រី៥នាក់ សរុបរួមមាន១០៧នាក់ស្ត្រី១៩នាក់។

o ថ្ងៃ០៦-១១ ខែសីហា ឆ្នាំ ២០១៨ នៅខេត្តត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង បានសម្របសម្រួលការរៀបចំបិទសេចក្តីសម្រេចរួមឆ្នាំ២០១៧ និងបញ្ចូលទិន្នន័យផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨របស់គម្រោងរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលខេត្ត រួមជាមួយរដ្ឋបាលក្រុង ស្រុក ។ គោលបំណងនៃការបិទបញ្ចប់សេចក្តីសម្រេចរួមឆ្នាំ២០១៧នេះ ដើម្បីលើកសេចក្តីព្រាងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៩បន្ត របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាសសភាពចូលរួមមាន ប្រធាន និងមន្ត្រីទីចាត់ការហិរញ្ញវត្ថុ និងរដ្ឋបាល និងក្រុមការងារថ្នាក់ជាតិ សរុបទាំងបីខេត្តចំនួន ២៨ ស្រី១២នាក់។

o ថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០១៨ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើម ភាគតិច បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជន ជាតិដើមភាគតិច នៅក្នុងគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ព្រមទាំង ផ្សព្វផ្សាយផ្នែកនេះនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ថ្មី ដល់មន្ត្រីដែលទើបចូលបម្រើការងារថ្មីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្តដែលនៅមិនទាន់បានចូលរួមក្នុងវគ្គនេះ មានសមាជិក សមាជិកាមកពីខេត្តចំនួនម្ភៃពីរដែលជានាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ជាប្រធាន អនុប្រធាន និងជាមន្ត្រីនៃការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ភាគច្រើនជាអ្នកអនុវត្តផ្ទាល់ជាមួយគម្រោង និងមន្ត្រីថ្មីដែលទទួលបន្ទុកគាំទ្រគម្រោងសរុបចំនួន៥៦នាក់ ស្ត្រី៥នាក់ ក្នុងនោះមន្ត្រី និងទីប្រឹក្សារបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន៧នាក់ស្ត្រី២នាក់។ គោលបំណងនៃកិច្ចប្រជុំ ដើម្បីកែលម្អចំណុចខ្វះចន្លោះដែលបានរកឃើញ និងបំពេញបន្ថែមចំណុចខ្វះចន្លោះទាំងនោះដែលបានអនុវត្តក្នុងរយៈពេល៩ខែកន្លងទៅ និងឆ្លើយតបចំពោះតម្រូវការជាក់ស្តែងនៅថ្នាក់ក្រោមជាតិ ព្រមទាំងផ្សារភ្ជាប់វគ្គផ្សព្វផ្សាយសៀវភៅភីមឃុំសង្កាត់ថ្មីស្តីពីកិច្ចការពារសុវត្ថិភាព បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ។



កិច្ចប្រជុំប្រចាំឆ្នាំស្តីពីស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៅក្នុងគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តឆ្នាំ២០១៨ នៅខេត្តមណ្ឌលគិរី

o ថ្ងៃទី០៥-០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខេត្តកំពង់ធំ បានចុះចូលរួមវាយតម្លៃគម្រោងមូលនិធិបន្សាំនឹងអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត(SRL)ទៅស្រុកគោលដៅចំនួន៥គឺ ស្រុកសន្ទុក ស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកសណ្ដាន់ និងស្រុកប្រាសាទបល្ល័ង្គ ។ គោលបំណងនៃការចុះនេះ គឺដើម្បីវាស់វែងទៅលើវិធីសាស្រ្ត និងការអភិវឌ្ឍសមត្ថភាពដែលស្រុកបានកែលម្អសមត្ថភាពរបស់ខ្លួនសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដើម្បីធ្វើការប្រៀបធៀបទៅនឹងលទ្ធផលវាយតម្លៃដើមគ្រាដែលស្រុកនីមួយៗបានចាប់ផ្តើមអនុវត្តមូលនិធិ PBCR ជាមូលដ្ឋានក្នុងការបែងចែក និងផ្តល់ថវិកាដោយផ្អែកលើលទ្ធផលនៃការអនុវត្តមូលនិធិ PBCR របស់គម្រោងឃុំ សង្កាត់ និងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តមូលនិធិ PBCRនេះរបស់ថ្នាក់ក្រោមជាតិ។ សមាសភាពចូលរួមវាយតម្លៃគម្រោងនេះរួមមាន មាន នាយក និងមន្រ្តីទីចាត់ការផែនការវិនិយោគខេត្ត, នាយករដ្ឋបាល និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ថ្នាក់ស្រុក, មេឃុំ និងក្រុមប្រឹក្សាឃុំ, ប្រជាពលរដ្ឋដែលទទួលផលពីគម្រោង, ទីប្រឹក្សាតំណាងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) និងក្រុមការងារគម្រោងSRL នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសរុបចំនួន៦៨នាក់ស្រី ២៩នាក់។



ចុះជួបប្រជុំជាមួយក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងមន្ត្រីបង្គោលគម្រោង
ដើម្បីពិនិត្យលើឯកសារវាយតម្លៃដើមគ្រានៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

o ថ្ងៃទី១២-១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខេត្តសៀមរាប បានចូលរួមចុះវាយតម្លៃគម្រោងមូលនិធិបន្សាំនឹងអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត(SRL)នៅក្នុងស្រុកចំនួន៥គឺ ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកប្រាសាទបាគង ស្រុកក្រឡាញ់ និងស្រុកវ៉ារិន។ គោលបំណងនៃការចុះនេះ គឺដើម្បីវាស់វែងទៅលើវិធីសាស្រ្ត និងការអភិវឌ្ឍសមត្ថភាពដែលស្រុកបានកែលម្អសមត្ថភាពរបស់ខ្លួនសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដើម្បីធ្វើការ

ប្រៀបធៀបទៅនឹងលទ្ធផលវាយតម្លៃដើមគ្រា និងដើម្បីបានចាប់ផ្តើមអនុវត្តមូលនិធិPBCR ឆ្នាំ២០១៩។ នាយក និងមន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត, នាយករដ្ឋបាល និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ថ្នាក់ស្រុក, មេឃុំ និងក្រុមប្រឹក្សាឃុំ, ប្រជាពលរដ្ឋដែលទទួលផលពីគម្រោង, ទីប្រឹក្សាតំណាងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) និងក្រុមការងារគម្រោងSRL នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសរុបចំនួន៧២នាក់ស្រី ៤៤នាក់។

- ថ្ងៃទី១៦-១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បានចូលរួមធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងបរិស្ថាន និងការធ្វើផែនការគ្រប់គ្រងបរិស្ថាន ដល់មន្ត្រី និងទីប្រឹក្សារបស់គម្រោង LASEDII នៅខេត្តកំពង់ឆ្នាំង ដែលមានមន្ត្រី និងទីប្រឹក្សារបស់គម្រោងនៅក្នុងខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ និងបាន ចូលរួមជាមួយមន្ត្រីផ្នែកសុវត្ថិភាពផ្នែកបរិស្ថាននិងសង្គមរបស់ធនាគារពិភពលោកចុះទៅបង្ហាត់បង្ហាញផ្ទាល់ដល់ទីតាំងគម្រោងចំពោះអ្នកអនុវត្តគម្រោងផងដែរ។



សកម្មភាពធ្វើបទបង្ហាញស្តីពីការអនុវត្តការគ្រប់គ្រង និងផែនការតាមដានបរិស្ថានដល់មន្ត្រី និងទីប្រឹក្សាគម្រោង LASED II នៅខេត្តកំពង់ឆ្នាំង

- ថ្ងៃទី២៧-២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខេត្តបន្ទាយមានជ័យ បានចូលរួមជាមួយក្រុមការងារនៃគម្រោងSRLចូលរួមក្នុងទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ស្តីពីការអនុវត្តគម្រោងកែលម្អជីវភាពរស់នៅដែលធន់នឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងបង្កើនសមត្ថភាព និងការយល់ដឹងរបស់កសិករតាមរយៈការសង្កេតមើលការចែករំលែក និងការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការកសាងភាពធន់ និងការកែលម្អជីវភាពរស់នៅក្នុងវិស័យកសិកម្មនិងទឹក និងមុខរបរក្រៅកសិកម្ម ដែលជាអំណោយផលដល់កសិករក្នុងឃុំគោលដៅ អាចរៀបចំផែនការអនុវត្តសាកល្បងនូវបទពិសោធន៍ដែលបានរៀនសូត្រ ព្រមទាំងមានគំនិតថ្មី

ទាក់ទងទៅនឹងគម្រោងដែលមានលក្ខណៈធន់ទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍របស់ខ្លួន។ សមាសភាពចូលរួមក្នុងទស្សនកិច្ចនេះមាន អនុប្រធានមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ មន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត នាយករដ្ឋបាល និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ មេឃុំ និងក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋដែលទទួលផលពីគម្រោង ទីប្រឹក្សាតំណាងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) និងក្រុមការងារគម្រោងSRL នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសរុបចំនួន ៨៥ នាក់ស្រី ៦៧នាក់ ។

o ថ្ងៃទី២៦-២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខេត្តក្រចេះ បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យភីដ(PID)នៃការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ដល់មន្ត្រីទទួលបន្ទុកការងារនេះនៅក្នុងទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទាំង២៥ ។ សិក្ខាសាលាមានគោលបំណងគាំទ្រ និងលើកកម្ពស់ការអនុវត្តប្រព័ន្ធទិន្នន័យព័ត៌មាននៃការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែប្រសើរ និងជួយពង្រឹងមន្ត្រីបង្គោលកាន់តែបានយល់ច្បាស់បន្ថែមទៀតអំពីបច្ចេកទេសក្នុងការបញ្ចូលទិន្នន័យព័ត៌មានគម្រោងឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ សិក្ខាសាលាមានអ្នកចូលរួមសរុបចំនួន៦០នាក់ស្រី៧នាក់។



មន្ត្រី និងទីប្រឹក្សាដែលចូលរួមសម្របសម្រួលក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ដល់មន្ត្រីទទួលបន្ទុកនៃទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត

o ថ្ងៃទី៤-៦ ខែធ្នូ ឆ្នាំ២០១៨ នៅខេត្តត្បូងឃ្មុំ បានចូលរួមសម្របសម្រួលជាមួយក្រុមការងារគម្រោងSRLចុះធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍នៃការអនុវត្តគម្រោងកែលម្អជីវភាពរស់នៅដែលធន់នឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលបំណងបង្កើនសមត្ថភាព និងការយល់ដឹងដល់កសិករក្នុងឃុំគោលដៅ តាមរយៈការសង្កេត ការចែករំលែក និងការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការកសាងភាពធន់ និងការកែលម្អជីវភាពរស់នៅក្នុងវិស័យកសិកម្មនិង

ទឹក និងមុខរបរក្រៅកសិកម្ម ព្រមទាំងអាចរៀបចំផែនការអនុវត្តសាកល្បងនូវបទពិសោធន៍ដែលទទួលបានពីការរៀនសូត្រ ដោយបង្កើតគំនិតថ្មីដែលមានលក្ខណៈធន់ នៅក្នុងសហគមន៍របស់ខ្លួន។ ទស្សនកិច្ចនេះ បានផ្សារភ្ជាប់ជាមួយគម្រោងកាត់បន្ថយភាពក្រីក្រនៅជុំវិញតំបន់បឹងទន្លេសាបដែលមានទីតាំងនៅក្នុងស្រុកព្រះនេត្រព្រះ មានអ្នកចូលរួមជាអនុប្រធានមន្ទីរកសិកម្មខេត្តត្បូងឃ្មុំ ក្រុមការងារគម្រោងTSDDខេត្តត្បូងឃ្មុំ មន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត នាយករដ្ឋបាល និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ថ្នាក់ស្រុក មេឃុំ និងក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋដែលទទួលផលពីគម្រោង ទីប្រឹក្សាអង្គការ UNDP ក្រុមការងារនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD) និងក្រុមការងារគម្រោងSRLថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិអ្នកចូលរួមសរុបចំនួន ១១៨ នាក់ស្រី ៦៧នាក់ ។

**២.៦. ការគាំទ្រ និងសហការនៅថ្នាក់ជាតិ៖**

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចបានសហការជាមួយមន្ត្រីនិងទីប្រឹក្សារបស់គម្រោងPBCR និងគម្រោងSRLជួយសម្របសម្រួលក្នុងសកម្មភាពដូចខាងក្រោម៖

- ថ្ងៃទី១៥-១៩ ខែមករា ឆ្នាំ២០១៨ បានចូលរួមប្រមូលទិន្នន័យបឋមការវាយតម្លៃការអនុវត្តមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្តPBCRGឆ្នាំ២០១៧របស់គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជាជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពជាអាទិភាព(SRL)នៅក្នុងខេត្តកំពង់ធំ។ ការចុះប្រមូលទិន្នន័យនេះ ដើម្បីបានជាទិន្នន័យគោលក្នុងការវាយតម្លៃការអនុវត្តមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្តរបស់ស្រុក។ ការប្រមូលទិន្នន័យដើមគ្រាចាំបាច់រៀបចំឡើង សម្រាប់ឆ្លុះបញ្ចាំងនូវសមត្ថភាពដឹកនាំអនុវត្ត និងគ្រប់គ្រងមូលនិធិរបស់ស្រុកនៅឆ្នាំបន្ទាប់ទៀត។ ក្នុងដំណើរការប្រមូលទិន្នន័យនេះ មានក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋចូលរួមមកពី០៥ស្រុក គឺស្រុកសន្ទុក ស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកសណ្ដាន់ និងស្រុកប្រាសាទបល្ល័ង្គ ចំនួនអ្នកចូលរួមសរុបចំនួន ៣១៩ នាក់ស្ត្រីចំនួន១២៩នាក់ ស្មើនិង៤០,៤៣%នៃអ្នកចូលរួមសរុប ។

- នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមក្នុងកិច្ចប្រជុំស្ដីពីការរៀបចំផែនការសកម្មភាពដើម្បីជ្រើសរើសភូមិដែលអាចចុះធ្វើការវាយតម្លៃគម្រោង របស់គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពជាអាទិភាព(SRL) ដែលមានសមាសភាពចូលរួមជាទីប្រឹក្សា និងមន្ត្រីរបស់ UNDP មន្ត្រីរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថាន(NCSD) និងមន្ត្រីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. (NCDDS) នៅសាលប្រជុំរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ សកម្មភាពនេះ បានចុះអនុវត្តន៍នៅក្នុងស្រុកចំនួន១០

របស់ខេត្តកំពង់ធំ និងខេត្តសៀមរាប ដោយបែងចែកក្រុមការងារចំនួន២ក្រុមចុះតាមភូមិនីមួយៗ។

- ថ្ងៃទី១៣-១៥ ខែមីនា ឆ្នាំ២០១៨ បានចូលរួមប្រជុំស្តីពីការរៀបចំធ្វើប៉ុសស្ទ័រ និងខិតប័ណ្ណផ្សព្វផ្សាយរបស់គម្រោង SRL និងបានចូលរួមធ្វើបទបង្ហាញស្តីពីការវាយតម្លៃគម្រោងប្រចាំឆ្នាំ លទ្ធផលវាយតម្លៃទិន្នន័យដើមគ្រា និងផែនការបន្ទាប់នៃគម្រោង SRL នៅក្នុងស្រុក ចំនួន១០របស់ខេត្តកំពង់ធំ និងខេត្តសៀមរាប ដែលមានអ្នកចូលរួមជានាយកទីចាត់ការផែនការ និងវិនិយោគខេត្ត អភិបាល អភិបាលរងស្រុក នាយក នាយករងរដ្ឋបាលស្រុក និងមន្ត្រី ការិយាល័យគាំទ្រមូលដ្ឋានខេត្តសរុបចំនួន៣៦នាក់។

- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ បានចូលរួមប្រជុំជាមួយក្រុមការងារគម្រោង SRL ដោយបានពិភាក្សាលើការជួយអនុវត្តគម្រោងរបស់ក្រុមហ៊ុន CADTIS មានដូចជា ផ្តល់សេវាកម្មនៅក្នុងភូមិគោលដៅ វាយតម្លៃលទ្ធផល និងគុណភាពគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ រៀបចំគណៈកម្មការប្រើប្រាស់ទឹក ក្រុមសន្សំ និងប្រើប្រាស់បច្ចេកទេសថ្មីបន្សាំទៅនឹងអាកាសធាតុក្នុងវិស័យកសិកម្ម។

- ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ បានចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពីការរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ចេញពីសៀវភៅភីមថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ GCF ដើម្បីឈានទៅជំហានទី៣។ លទ្ធផលជារួម ថ្នាក់ដឹកនាំបានឲ្យក្រុមការងាររៀបចំឱ្យបានលឿន មុនពេលដែលក្រុមGCFចុះមកវាយតម្លៃម្តងទៀត។ ក្រុមការងារក្នុងអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីបានបន្តប្រជុំរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ GCF ដោយបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ និងកែសម្រួលពាក្យពេចន៍។

- ថ្ងៃទី០៤-០៧ ខែកញ្ញា ឆ្នាំ២០១៨ បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ សម្រាប់តាមដានកម្មវិធី និងការវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅខេត្តតាកែវ ក្រោមជាតិរៀបចំដោយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី។ វគ្គនេះរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ និងបញ្ចូលសូនាករបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យ និងការប្រមូលទិន្នន័យសម្រាប់សូចនាការបន្សាំ។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងផែនការ អភិបាលរងខេត្ត ថ្នាក់ដឹកនាំអង្គភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប. និងតំណាងទីចាត់ការផែនការ និងវិនិយោគមកពីខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តព្រះសីហនុ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំសរុបចំនួន១០៥នាក់ស្រី២១នាក់។

o ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ បានចូលរួមពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ(SPCR) ដែលសម្រេចបោះពុម្ព។

o ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ បានចូលរួមប្រជុំនៅសាលប្រជុំរបស់លេខាធិការដ្ឋាន ជាមួយក្រុមផលិតវីដេអូឯកសាររបស់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប ធ្វើការពិនិត្យផ្តល់យោបល់កែលម្អលើរូបភាព និងខ្លឹមសារមួយចំនួននៃវីដេអូចំនួន៦ដែលបានផលិតរួចសម្រាប់ផ្សព្វផ្សាយជាសាធារណៈនៅតាមបណ្តាញផ្សព្វផ្សាយ។

o ថ្ងៃទី១២-១៣ ខែតុលា ឆ្នាំ២០១៨ បានចូលរួមជាមួយមន្ត្រីនិងទីប្រឹក្សាគម្រោងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជុំវិញតំបន់បឹងទន្លេសាប(TSSD) មន្ត្រីបង្គោលថ្នាក់ខេត្ត ចុះសិក្សាផលប៉ះពាល់បរិស្ថាន និងដីធ្លីរបស់ប្រជាពលរដ្ឋនៅឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ដែលជាគម្រោងផ្លូវក្រាលក្រួសក្រហមក្រោមការផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

o ថ្ងៃទី២២-២៦ ខែតុលា ឆ្នាំ២០១៨ បានចូលរួមជាមួយក្រុមការងារគម្រោង ASPIRE ដើម្បីស្រង់ទិន្នន័យដើមគ្រារបស់គម្រោងនៅក្នុងខេត្តព្រៃវែង ដែលមានគម្រោងនៅក្នុងស្រុកចំនួន ៣ គឺស្រុកកញ្ជ្រៀច ស្រុកកំចាយមារ និងស្រុកបាភ្នំ និងបានចុះជួបជាមួយក្រុមប្រឹក្សាឃុំ ជួបជាមួយប្រជាពលរដ្ឋនៅក្នុង៦ឃុំ ធ្វើសម្ភាសន៍ ស្រង់ទិន្នន័យសម្រាប់ ដើម្បីជាទិន្នន័យគោលវាយតម្លៃគម្រោងនៅចុងឆ្នាំ២០១៨។



ក្រុមការងារចុះប្រមូលទិន្នន័យដើមគ្រាក្នុងឃុំមួយចំនួនក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង

## ៣. បញ្ហាប្រឈមនានា

ក្នុងឆ្នាំ២០១៨នេះ ទីចាត់ការផែនការ និងវិនិយោគខេត្តបានផ្ញើបញ្ជីគម្រោង និងឯកសាររបាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចមានភាពយឺតយ៉ាវជាងឆ្នាំមុនៗ។ ខេត្តព្រៃវែងមិនបានផ្ញើបញ្ជីគម្រោង និងឯកសាររបាយការណ៍គម្រោងមកលេខាធិការដ្ឋានទេ ខេត្តកណ្តាល និងខេត្តឧត្តរមានជ័យផ្ញើតែបញ្ជីគម្រោងតែមិនមានឯកសាររបាយការណ៍វិភាគបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងផ្ញើមកក្រុមការងារនៃលេខាធិការដ្ឋានដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស។

ឆ្លងតាមកិច្ចប្រជុំរយៈពេលពីរថ្ងៃនៅក្នុងខេត្តមណ្ឌលគិរី សមាជិក សមាជិកានៃកិច្ចប្រជុំទាំងអស់បានលើកឡើងនូវភាពខ្វះចន្លោះខ្លះក្នុងការអនុវត្តគម្រោងដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- កម្មវិធី ផអ៣ សម្រាប់សេវាមន្ត្រីកិច្ចសន្យា និងទីប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវបានបញ្ចប់នៅចុងឆ្នាំ២០១៧ នាំឱ្យការគាំទ្រគម្រោងមានការពន្យាពេល
- មន្ត្រីដែលទទួលការងារសិក្សាគម្រោងជាមន្ត្រីថ្មីនៅមិនទាន់មានបទពិសោធន៍សិក្សាគម្រោងនៅឡើយ
- មានឧបករណ៍ និងសម្ភារសម្រាប់ចុះសិក្សាគម្រោងមានសភាពចាស់ៗ ខ្លះខូចប្រើមិនកើតទាំងស្រុង
- ទីចាត់ការផែនការ និងវិនិយោគមិនមានកញ្ចប់ថវិកាជាមធ្យោបាយសម្រាប់មន្ត្រីប្រើប្រាស់ចុះសិក្សាគម្រោង
- ការសិក្សាដីធ្លីមានភាពយឺតយូរក្នុងការបញ្ចប់របាយការណ៍ដោយសារតែពិបាកអញ្ជើញប្រជាពលរដ្ឋជាម្ចាស់ក្បាលដីនីមួយៗចូលរួមប្រជុំ និងផ្តិតមេដៃព្រមព្រៀង ហើយមានម្ចាស់ក្បាលដីចម្ការខ្លះមានទីលំនៅឆ្ងាយពីខេត្ត
- ការយល់ដឹងអំពីគោលការណ៍ណែនាំអនុវត្តន៍គម្រោងក្នុងសៀវភៅភីមរបស់មន្ត្រីទទួលបន្ទុកថ្មីនៅមានកម្រិតទាបនៅឡើយ
- អូសបន្លាយពេលវេលាសិក្សាគម្រោង ដោយសារឃុំ សង្កាត់ទាំងអស់មានកាតព្វកិច្ចរៀបចំការបោះឆ្នោតសកលហើយមិនបានឱ្យបានជិតដល់ក្នុងការសិក្សាគម្រោង
- មានមន្ត្រីមិនគ្រប់គ្រាន់សម្រាប់ចុះគាំទ្រគម្រោងក្រុង ស្រុក និងគម្រោងខេត្ត
- សមត្ថភាពមន្ត្រីគាំទ្របច្ចេកទេសថ្នាក់ខេត្តនៅមានកម្រិតនៅឡើយ
- មានមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់នៅក្នុងទីចាត់ការផែនការ និងវិនិយោគខេត្ត ដែលមានតួនាទីចុះសិក្សាគម្រោងរួមគ្នាជាមួយមន្ត្រីទទួលបន្ទុកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់ខេត្ត។

## ៤. ការសន្និដ្ឋាន

ក្រុមការងារបានអនុវត្តការងារស្របទៅតាមផែនការសកម្មភាព ដែលបានគ្រោងទុក មានដូចជា ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើរបាយការណ៍ វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តឆ្នាំ២០១៨មុនពេលដេញថ្លៃ។

ត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លី គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ របស់ខេត្តរតនគិរីដែលបានអនុវត្តគម្រោងរួចរាល់ ដើម្បីប្រាកដថាបានអនុវត្តន៍តាមការណែនាំតាមសៀវភៅភីម។ ជាលទ្ធផល មន្ត្រីពាក់ព័ន្ធនឹងការអនុវត្តគម្រោងបានអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីរបស់គម្រោងត្រឹមត្រូវតាមគោលការណ៍ណែនាំ ហើយបានដោះស្រាយបញ្ហារហូតបានអនុវត្តគម្រោងរួចរាល់ស្អាត។ ការចុះត្រួតពិនិត្យរបាយការណ៍ និងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីរបស់គម្រោងឃុំសង្កាត់នៅក្នុងខេត្តរតនគិរី ឃើញមានការកែប្រែច្រើនជាងមុន ដោយសារការបំពេញឯកសាររបាយការណ៍មានភាពខ្វះចន្លោះតិចតួច ហើយការអនុវត្តនៅទីតាំងគម្រោងមានតម្លាភាពជាមួយប្រជាពលរដ្ឋ។ ការចុះត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លីបានតែមួយខេត្តនេះ ដោយសារនៅឃុំសង្កាត់ត្រូវរៀបចំការបោះឆ្នោតសកល ក្រុមការងារត្រូវរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមឆ្លងថ្នាក់ដឹកនាំ។

ក្រុមការងារកិច្ចការពារសុវត្ថិភាព ប.ដ.ដ. បានបានពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមតាមរយៈការចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់លើបរិស្ថាន និងសង្គមដែលរៀបចំដោយក្រុមការងារនៃធនាគារពិភពលោក(WB) ចូលរួមក្នុងការប្រជុំជាមួយមន្ត្រី និងទីប្រឹក្សាជំនាញផ្នែកការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន។

នៅថ្នាក់ជាតិក្រុមការងារបានចូលរួមក្នុងសកម្មភាពគាំទ្រ និងសហការជាមួយមន្ត្រី និងទីប្រឹក្សាគម្រោងកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព(SRL) គម្រោងរបស់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានដូចជា ចូលរួមប្រជុំរៀបចំផែនការចុះប្រមូលទិន្នន័យវាយតម្លៃការអនុវត្តមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្តរបស់ស្រុកនៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប ចូលរួមក្នុងកិច្ចប្រជុំស្តីពីការរៀបចំផែនការសកម្មភាព ដើម្បីជ្រើសរើសភូមិដែលអាចចុះធ្វើការវាយតម្លៃគម្រោងរបស់គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពជាអាទិភាព(SRL) បានចូលរួមប្រជុំស្តីពីការរៀបចំធ្វើប៉ុសស្ទ័រ និងខិតប័ណ្ណផ្សព្វផ្សាយរបស់គម្រោង SRL និងបានចូលរួមធ្វើបទបង្ហាញស្តីពីការវាយតម្លៃគម្រោងប្រចាំឆ្នាំ លទ្ធផលវាយតម្លៃទិន្នន័យដើមគ្រា និងផែនការបន្ទាប់នៃគម្រោង SRL នៅក្នុងស្រុកចំនួន១០ របស់ខេត្តកំពង់ធំ និងខេត្តសៀមរាប, បានចូលរួមប្រជុំជាមួយក្រុមការងារគម្រោងSRLដោយបានពិភាក្សាលើការជួយអនុវត្តគម្រោងរបស់ក្រុមហ៊ុនCADTIS មានដូចជា ផ្តល់សេវាកម្មនៅក្នុងភូមិគោលដៅ វាយតម្លៃលទ្ធផល និងគុណភាពគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ រៀបចំគណៈកម្មការ

ប្រើប្រាស់ទឹក ក្រុមសន្សំ និងប្រើប្រាស់បច្ចេកទេសថ្មីបន្សាំទៅនឹងអាកាសធាតុក្នុងវិស័យកសិកម្ម, បានចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប. ស្តីពីការរៀបចំគោលការណ៍ណែនាំស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចមួយចេញពីសៀវភៅភីមថ្មីដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ GCF ដើម្បីឈានទៅជំហានទី៣, បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការត្រួតនិត្យ និងវាយតម្លៃ សម្រាប់តាមដានកម្មវិធី និងការវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅខេត្តតាកែវ រៀបចំដោយអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី, បានចូលរួមពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីមូលនិធិផ្អែកលើលទ្ធផលនៃការអនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ(SPCR)ដែលសម្រេចបោះពុម្ព ចូលរួមជាមួយមន្ត្រីនិងទីប្រឹក្សាគម្រោងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជុំវិញតំបន់បឹងទន្លេសាប(TSSD) មន្ត្រីបង្គោលថ្នាក់ខេត្ត ចុះសិក្សាផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់លើសុវត្ថិភាពដីធ្លីរបស់ប្រជាពលរដ្ឋនៅឃុំបាជាយ ស្រុកបាជាយ ខេត្តកំពង់ចាម, និងបានចូលរួមជាមួយក្រុមការងារគម្រោង ASPIRE ដើម្បីស្រង់ទិន្នន័យដើមគ្រារបស់គម្រោងនៅក្នុងខេត្តព្រៃវែង នៅក្នុងស្រុកចំនួន៣គឺស្រុកកញ្ជ្រៀចស្រុកកំចាយមារនិងស្រុកបាភ្នំ។

ចំពោះសកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ ក្រុមការងារបានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយអំពីការបំពេញទម្រង់ និងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងនៅក្នុងសៀវភៅភីមថ្មី ដល់មន្ត្រីនិងទីប្រឹក្សាអនុវត្តន៍គម្រោង SRL ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប សម្រាប់សិក្សាតម្រូវការកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង និងបំពេញទម្រង់គម្រោងឱ្យបានត្រឹមត្រូវបានចូលរួមគាំទ្រសកម្មភាពសម្រាំងជ្រើសរើសអ្នកទទួលផលរបស់គម្រោងSRL នៅក្នុងស្រុកគោលដៅទាំងដប់នៃខេត្តកំពង់ធំ បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេត និងការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm, បានចូលរួមសម្របសម្រួលនិងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុនៅខេត្តបាត់ដំបង លើប្រធានបទកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងឃុំសង្កាត់ ដល់មន្ត្រីអនុវត្តគម្រោង, បានចូលរួមធ្វើបទបង្ហាញ និងសម្របសម្រួលក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពី"ការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ"នៅខេត្តកំពង់ធំ និងខេត្តសៀមរាប, បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចនៅក្នុងគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ព្រមទាំងផ្សព្វផ្សាយផ្នែកនេះនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ថ្មី ដល់មន្ត្រីដែលទើបចូលបម្រើការងារថ្មីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត, បានចូលរួមធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងបរិស្ថាន និងការធ្វើផែនការគ្រប់គ្រងបរិស្ថាន ដល់មន្ត្រី និងទីប្រឹក្សារបស់គម្រោង LASEDII នៅខេត្តកំពង់ឆ្នាំង,និងបានចូលរួមធ្វើបឬបង្ហាញក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យភីដ(PID)ផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ដល់មន្ត្រីទទួលបន្ទុកការងារនេះនៅក្នុងទីចាត់ការផែនការ និងវិនិយោគទាំង២៥រាជធានី ខេត្ត។

## ៥. អនុសាសន៍ និងសំណូមពរ

ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដើម្បីឱ្យឆ្លើយតបតាមគោលការណ៍ណែនាំ ក្រុមការងារ ប.ដ.ជ. មានអនុសាសន៍ដូចខាងក្រោម៖

- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ត្រូវបង្កើនកិច្ចសហការគ្នា ចុះតាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោងឱ្យបានជិតដល់
- មន្ត្រីគាំទ្រគម្រោងដែលទទួលខុសត្រូវនៅក្នុងឃុំសង្កាត់របស់ខ្លួន ត្រូវខិតខំស្វែងយល់ពីការសិក្សាសុវត្ថិភាពគម្រោងឱ្យស្ទាត់ជំនាញសម្រាប់ជួយគាំទ្រគម្រោង
- ខេត្តគួរពិនិត្យលទ្ធភាពក្នុងផ្តល់ការហ្វឹកហ្វឺនបន្ថែម ដល់មន្ត្រីពាក់ព័ន្ធនឹងការគាំទ្រគម្រោង ពិសេសមន្ត្រីថ្មី បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានាផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចឱ្យមានសមត្ថភាពពេញលេញជួយគាំទ្រគម្រោង
- ខេត្តគួរពិចារណាលទ្ធភាពផ្តល់ឧបករណ៍ សម្ភារ និងមធ្យោបាយគ្រប់គ្រាន់ដល់ទីចាត់ការផែនការ និងវិនិយោគសម្រាប់ចុះគាំទ្រគម្រោង
- ខេត្តគួរមានកញ្ចប់ថវិកាដល់មន្ត្រីទទួលបន្ទុកក្នុងទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីរបស់មន្ទីរពាក់ព័ន្ធដែលមានការងារចុះគាំទ្រគម្រោង
- ខេត្តគួរមានការតែងតាំងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តបន្ថែមទៀត ដើម្បីបានចុះសិក្សាគម្រោងរួមគ្នាជាមួយមន្ត្រីទទួលបន្ទុកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៩

ផែនការសកម្មភាពសម្រាប់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប មានដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ សម្រាប់ក្រុមការងារ ប.ដ.ជ.
- នៅដើមឆ្នាំចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ដើម្បីពង្រឹងការងារនេះ
- ទំនាក់ទំនងជាមួយទីចាត់ការផែនការ និងវិនិយោគខេត្ត ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ងាយស្រួលក្នុងការពិនិត្យ និងផ្តល់យោបល់បច្ចេកទេស
- បន្តកែសម្រួល និងរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជាមួយថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប.

- លើកសំណើសុំកិច្ចសហការពីក្រុមទីប្រឹក្សាបច្ចេកទេសនៃធនាគារពិភពលោក(The World Bank) ដើម្បីបានជួយកែសម្រួលលើសេចក្តីព្រាងគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម
- ចូលរួមតាមការអញ្ជើញរបស់ថ្នាក់ក្រោមជាតិដើម្បីជួយសម្របសម្រួលក្នុងវគ្គរំលឹកឡើងវិញ ឬវគ្គបណ្តុះបណ្តាលនានាស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចនៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តផ្សារភ្ជាប់និងវគ្គរំលឹកឡើងវិញ
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ និងប្រចាំឆ្នាំដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

**រៀបចំដោយ**

**ក្រុមការងារកិច្ចការពារសុវត្ថិភាព ប.ដ.ជ. នៃលេខាធិការដ្ឋាន គ.ជ.អ.ប.**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
លេខាធិការដ្ឋាន (គ.ជ.អ.ប)

អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខ: ......០០៥............./អ.គ.គ.ក

ថ្ងៃ.អង្គារ...៣.កើត......ខែ.បុស្ស..ឆ្នាំ.ច..សំរឹទ្ធិស័ក...ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី....០៨......... ខែ.មករា...... ...ឆ្នាំ២០១៩..

## សូមគោរពជូន
## ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.

**កម្មវត្ថុ** ៖ របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចប្រចាំឆ្នាំ២០១៨ ។

**យោង** ៖ ផែនការសកម្មភាពរបស់លេខាធិការដ្ឋានគ.ជ.អ.ប. ឆ្នាំ២០១៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាកិច្ចការដ៏សំខាន់មួយ ដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់នៅថ្នាក់ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោងផងដែរ។ ក្នុងឆ្នាំ២០១៨នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដែលមានមន្ត្រី និងទីប្រឹក្សាបានបំពេញការងាររបស់ខ្លួនតាមផែនការសកម្មភាព និងថវិកាដែលបានកំណត់ និងទទួលបានលទ្ធផលមានដូចខាងក្រោម៖

១. បានសម្របសម្រួលជាមួយនាយក នាយករង និងមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចខេត្ត បានរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក គម្រោងខេត្តឆ្នាំ២០១៨ និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងនេះរៀងរាល់ខែទៅតាមថ្នាក់ក្រោមជាតិដែលបានស្នើឡើង។ បញ្ជីគម្រោងទាំងនោះមានដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសរុបមានចំនួន១៦៨៤គម្រោងនៃ១៥៣៧ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបមានចំនួន៦៨៩គម្រោង តម្រូវការសិក្សាដីធ្លីសរុបមានចំនួន៣៦៥គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបមានចំនួន៥៩គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន៦៦៧គម្រោង និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចសរុបមានចំនួន៥៩គម្រោង។

ខ).គម្រោងមូលនិធិក្រុង ស្រុក មានខេត្តចំនួន១៥ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៨ មានចំនួនសរុប២៦៧គម្រោងនៃ១៥៤ក្រុង ស្រុក។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន១៤០គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន១៩គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន៤៨គម្រោង។ គម្រោង

ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន១៤២គម្រោង និងនៅក្នុងតំបន់ជនជាតិដើមភាគតិចសរុបចំនួន៤៨គម្រោង។

គ). មានតែខេត្តកែប និងខេត្តប៉ៃលិន ដែលបានអនុវត្តគម្រោងខេត្តបានសរុបចំនួន១៥គម្រោង ក្នុងនោះតម្រូវការសិក្សាបរិស្ថានមានចំនួន១៥គម្រោង មិនមានតម្រូវការសិក្សាដីធ្លីនិងសិក្សាជនជាតិដើមភាគតិចទេ។ ខេត្តផ្សេងៗទៀតមិនបានផ្ញើបញ្ជី និងឯកសាររបាយការណ៍របស់គម្រោងមកក្រុមការងារនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ឡើយ។

២. បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតនៅក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិចមុនដេញថ្លៃគម្រោង មានដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប៤១៧គម្រោង ស្មើនឹង៦៣%នៃចំនួនសរុប៦៦៧គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន៤៤គម្រោង ស្មើនឹង ៧៥% នៃចំនួន៥៩គម្រោង ដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។ ក្នុងនេះ មានគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានដែលហៅកាត់ថា ASPIRE ភ្ជាប់ជាមួយគម្រោងឃុំ សង្កាត់ផងដែរ។

ខ).បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតនៅក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានសរុបចំនួន៩៣គម្រោងស្មើនឹង៦៥%នៃ១៤២គម្រោងនិងរបាយការណ៍ការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន៤៨គម្រោងស្មើនឹង៧៤%នៃ៥៩គម្រោង។

គ).បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្តកែប និងខេត្តប៉ៃលិនលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានសរុបចំនួន១៥គម្រោងស្មើនឹង១០០%នៃគម្រោងសរុបចំនួន១៥គម្រោង និងមិនមានគម្រោងទាក់ទងទៅនឹងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចទេ។

៣. បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគខេត្តរតនគិរី ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្រុមការងារបានពិនិត្យគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៧របស់ខេត្តរតនគិរី ក្នុងនោះគម្រោងស្នើឡើងសរុបចំនួន៤៨គម្រោង គម្រោងតម្រូវការសិក្សាដីធ្លីមានចំនួន១៥គម្រោង។ ក្នុងគម្រោងសរុបចំនួន៤៨នេះ បានចុះកិច្ចសន្យានិងអនុវត្តន៍បាន១០០%ទាំងអស់។ គម្រោងដែលបានត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីសរុបចំនួន១៥គម្រោងស្មើនឹង១០០%នៃគម្រោងសិក្សាដីធ្លីទាំងអស់។ សង្កេតឃើញថា ការបំពេញឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីគម្រោងឃុំសង្កាត់ឆ្នាំ២០១៧របស់ខេត្ត មានការយកចិត្តទុកដាក់បានល្អជាងមុន។

៤. ការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ៖ បានចូលរួមក្នុងសិក្ខាសាលាស្តីពីការពង្រឹងការអនុវត្តកិច្ចការពារហានិភ័យបរិស្ថាន និងសង្គមនៅកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងរាជធានីភ្នំពេញ ដែលរៀបចំដោយក្រុមការងារកិច្ច

ការពារសុវត្ថិភាពបរិស្ថាន និងសង្គមនៃធនាគារពិភពលោក(The World Bank) មានអ្នកចូលរួមមកពីស្ថាប័នក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក ក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.អ.ប សរុបចំនួន៥០នាក់។ នៅក្នុងសិក្ខាសាលានេះ មានបទបង្ហាញចំនួនពីរប្រធានបទគឺ៖ ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម(E&S)នៅកម្ពុជា និងការឈានទៅកែលម្អការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងវិនិយោគនានានៅកម្ពុជា។

៥. ការពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ៖

- បានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយអំពីការបំពេញទម្រង់ទាក់ទងទៅនឹងការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់សៀវភៅគឹមថ្មី ដល់មន្ត្រី និងទីប្រឹក្សាអនុវត្តន៍គម្រោងSRL ក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប សម្រាប់សិក្សាតម្រូវការ និងបំពេញទម្រង់ឱ្យបានត្រឹមត្រូវ
- បានចូលរួមគាំទ្រសកម្មភាពសម្រាំងជ្រើសរើសអ្នកទទួលផលរបស់គម្រោងSRL នៅក្នុងស្រុកគោលដៅទាំងដប់នៃខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន៧១២នាក់ស្រី៥៥៦នាក់
- បានចូលរួមសម្របសម្រួលរៀបចំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេត និងការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm នៅខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន ៣៦នាក់ស្រី១៧នាក់ ដែលជានាយករងរដ្ឋបាលខេត្ត នាយករដ្ឋបាលស្រុក មន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់នៃស្រុកសន្ទុក ស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកសណ្តាន់ និងស្រុកប្រាសាទបល្ល័ង្គ ក្រុមការងារក្រុមហ៊ុន GIS Firm ទីប្រឹក្សាតំណាង UNDP ក្រុមការងារប្រឹក្សាអគ្គលេខាធិការដ្ឋានអភិវឌ្ឍន៍ដោយចីរភាព និងក្រុមការងារគម្រោង SRL ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានចូលរួមរៀបចំកិច្ចប្រជុំនៅខេត្តសៀមរាប ដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេត ការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីការចុះអង្កេតការប្រមូលទិន្នន័យដើមគ្រា( Project Baseline Survey) នៅតាមឃុំគោលដៅរបស់ក្រុមហ៊ុន GIS Firm សម្រាប់ជាគោលយកជាគោលធ្វើការវាយតម្លៃគម្រោង កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន៣៨នាក់ស្រី១៥នាក់ ជាទីប្រឹក្សា UNDP និងក្រុមការងារគម្រោងSRL ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នាយករងរដ្ឋបាលសាលាខេត្ត នាយករដ្ឋបាលស្រុក មន្ត្រីទីចាត់ការផែនការវិនិយោគខេត្ត និងប្រធានការិយាល័យគាំទ្រឃុំ សង្កាត់ថ្នាក់ស្រុកដែលមកពីស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកប្រាសាទបាគង ស្រុកក្រឡាញ់ ស្រុកវ៉ារិន
- បានចូលរួមសម្របសម្រួលនិងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុនៅខេត្តបាត់ដំបង លើប្រធានបទកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងឃុំ សង្កាត់ ដល់មន្ត្រីអនុវត្តគម្រោងក្នុងស្រុកគោលដៅដែលមកពី១២ខេត្តមានអ្នកចូលរួមសរុបចំនួន២៤នាក់ ដែលមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត
- បានចូលរួមធ្វើបទបង្ហាញ និងសម្របសម្រួលក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពី"ការរៀបចំនិងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ" ដែលផ្តោតលើប្រធានបទចំនួនពីរគឺទី១)."ការអនុវត្តមូលនិធិបន្សាំទៅនឹង ការប្រែប្រួលអាកាសធាតុ(PBCR Grant)" និងទី២)."ការចាត់ថ្នាក់មុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម"

ក្នុងគម្រោង SRL នៅខេត្តកំពង់ចាម ដែលមានមន្ត្រី និងទីប្រឹក្សាចូលរួមសរុបចំនួន៤០នាក់ស្រី៨នាក់ មកពីស្រុកគោលដៅចំនួន១០របស់ខេត្តកំពង់ធំ និង ខេត្តសៀមរាប

- បានចូលរួមសម្របសម្រួល និងធ្វើបទបង្ហាញក្នុងកម្មវិធីសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការ"រៀបចំ និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ" នៅខេត្តព្រៃវែង លើប្រធានបទ "កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងឃុំ សង្កាត់" ក្នុងសៀវភៅកឹម កែសម្រួលថ្មី និងប្រកាសឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០១៨ ដែលមានសិក្ខាកាមមកពីស្រុកគោលដៅទាំង ៨ប់របស់ខេត្តព្រៃវែង និងមកពីទីចាត់ការផែនការ និងវិនិយោគខេត្ត សរុបចំនួន៤០នាក់ស្រី៦នាក់
- បានចូលរួមធ្វើបទបង្ហាញផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងសៀវភៅ កឹមឃុំ សង្កាត់ថ្មី នៅខេត្តសៀមរាប ដែលមានសិក្ខាកាមជាមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្ត មកពីខេត្តចំនួន៨គឺ ខេត្តកំពត ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រះវិហារ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តព្រៃវែង និងខេត្តស្វាយរៀង មានស្រុកគោលដៅចំនួន២៤ និងមានអ្នកចូលរួមសរុបចំនួន ៧៥នាក់ស្រី១១នាក់
- បានចូលរួមធ្វើបទបង្ហាញផ្សព្វផ្សាយកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិចក្នុង សៀវភៅកឹមថ្មីសម្រាប់អនុវត្តក្នុងគម្រោង (PBCR Grant) សម្រាប់ ខេត្តព្រៃវែង និងខេត្តបាត់ដំបង។ មានសិក្ខាកាមចូលរួមសរុបមាន២២៣នាក់ស្រី៤៥នាក់
- នៅខេត្តត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង បានសម្របសម្រួលជាមួយមន្ត្រីថ្នាក់ជាតិ ជាមួយរដ្ឋបាលខេត្ត និងក្រុង ស្រុក ដើម្បីបិទបញ្ចប់សេចក្តីសម្រេចរួមឆ្នាំ២០១៧ និងលើកសេចក្តីព្រាងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៥បន្ត របស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានអ្នកចូលរួមសរុបទាំងបីខេត្តចំនួន ២៨ ស្រី១២នាក់
- បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើម ភាគតិច នៅក្នុងគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ព្រមទាំងផ្សព្វផ្សាយ ផ្នែកនេះនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ថ្មី ដល់មន្ត្រីដែលទើបចូល បម្រើការងារថ្មីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្តដែលនៅមិនទាន់បានចូលរួមក្នុងវគ្គនេះ មាន អ្នកចូលរួមមកពីខេត្តចំនួនម្ភៃពីរដែលជានាយក នាយករងទីចាត់ការផែនការ និងវិនិយោគ ប្រធាន អនុប្រធាន និងជាមន្ត្រីនៃការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ដែលអនុវត្តផ្ទាល់ជាមួយគម្រោង និង មន្ត្រីថ្មីសរុបចំនួន៥៦នាក់ ស្រី៥នាក់
- បានចូលរួមធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងបរិស្ថាន និងការធ្វើផែនការគ្រប់គ្រងបរិស្ថាន ដល់មន្ត្រី និង ទីប្រឹក្សារបស់គម្រោង LASED II នៅខេត្តកំពង់ឆ្នាំង ដែលមានមន្ត្រី និងទីប្រឹក្សារបស់គម្រោងនៅក្នុង ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ និងបាន ចូលរួមជាមួយមន្ត្រី ផ្នែកសុវត្ថិភាពផ្នែកបរិស្ថាននិងសង្គមរបស់ធនាគារពិភពលោកចុះទៅបង្ហាត់បង្ហាញផ្ទាល់ដល់ទីតាំង គម្រោងចំពោះអ្នកអនុវត្តគម្រោងផងដែរ មានអ្នកចូលរួមសរុបចំនួន២០នាក់ស្រី៤នាក់
- នៅខេត្តបន្ទាយមានជ័យ បានចូលរួមជាមួយក្រុមការងារនៃគម្រោងSRLចូលរួមក្នុងទស្សនកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍ស្តីពីការអនុវត្តគម្រោងកែលម្អជីវភាពរស់នៅដែលធន់នឹងការប្រែប្រួលអាកាស ធាតុ ក្នុងគោលបំណងបង្កើនសមត្ថភាព និងការយល់ដឹងរបស់កសិករតាមរយៈការសង្កេតមើលការ ចែករំលែក និងការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការកសាងភាពធន់ និងការកែលម្អជីវភាពរស់នៅក្នុង វិស័យកសិកម្មនិងទឹក និងមុខរបរក្រៅកសិកម្ម មានអ្នកចូលរួមសរុបចំនួន ៨៥ នាក់ស្រី ៦៧នាក់

- បានចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីប្រព័ន្ធទិន្នន័យគីដ(PID)នៃការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ដល់មន្ត្រីទទួលបន្ទុកការងារនេះនៅក្នុងទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តទាំង២៥ នៅសាលប្រជុំខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុបចំនួន៦០នាក់ស្រី៧នាក់ ក្នុងគោលបំណងគាំទ្រនិងលើកកម្ពស់ការអនុវត្តប្រព័ន្ធទិន្នន័យព័ត៌មាននៃការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងជួយពង្រឹងមន្ត្រីបង្គោលកាន់តែបានយល់ច្បាស់បន្ថែមទៀតអំពីបច្ចេកទេសក្នុងការបញ្ចូលទិន្នន័យព័ត៌មានគម្រោងឱ្យបានត្រឹមត្រូវ

៦.ការគាំទ្រ និងសហការនៅថ្នាក់ជាតិ៖ បានចូលរួមជាមួយមន្ត្រី និងទីប្រឹក្សានៅថ្នាក់ជាតិចូលរួមប្រមូលទិន្នន័យបឋមការវាយតម្លៃការអនុវត្តមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើលទ្ធផលនៃការអនុវត្ត(PBCRG) ឆ្នាំ២០១៧របស់គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជាជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ រៀបចំផែនការសកម្មភាព ដើម្បីជ្រើសរើសភូមិដែលអាចចុះធ្វើការវាយតម្លៃគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពជាអាទិភាពរបស់គម្រោងSRL រៀបចំធ្វើប៉ុស្ទ័រ និងខិតប័ណ្ណផ្សព្វផ្សាយរបស់គម្រោង SRL និងបានចូលរួមធ្វើបទបង្ហាញស្តីពីការវាយតម្លៃគម្រោងប្រចាំឆ្នាំលទ្ធផលវាយតម្លៃទិន្នន័យដើមគ្រា និងផែនការបន្ទាប់នៃគម្រោងSRL ប្រជុំជាមួយថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប. ស្តីពីការរៀបចំគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម ចេញពីសៀវភៅគឹមដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់GCFជំហានទី៣ ចូលរួមជាមួយមន្ត្រីនិងទីប្រឹក្សាគម្រោងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជុំវិញតំបន់បឹងទន្លេសាប (TSSD) មន្ត្រីបង្គោលថ្នាក់ខេត្ត ចុះសិក្សាផលប៉ះពាល់បរិស្ថាន និងដីធ្លីរបស់ប្រជាពលរដ្ឋនៅឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម និងចូលរួមជាមួយក្រុមការងារគម្រោង ASPIRE ដើម្បីស្រង់ទិន្នន័យដើមគ្រារបស់គម្រោងនៅក្នុងខេត្តព្រៃវែងចំនួន១០លើក។

តាមរយៈការចុះត្រួតពិនិត្យសុវត្ថិភាពដីធ្លីក្រោយការអនុវត្តគម្រោង តាមរយៈការប្រជុំប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាព និងតាមរយៈការអនុវត្តការងារជាក់ស្តែងនៅថ្នាក់ជាតិ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជួបបញ្ហាមួយចំនួនដែលធ្វើឱ្យមានការពន្យាពេលសិក្សា និងអនុវត្តគម្រោងបានទាន់ពេលវេលា ។ បញ្ហាទាំងនោះមានដូចខាងក្រោម៖

- សេវាមន្ត្រីកិច្ចសន្យា និងទីប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវបានបញ្ចប់នៅចុងឆ្នាំ២០១៧ នាំឱ្យមិនមានមន្ត្រីគ្រប់គ្រាន់ជួយគាំទ្រគម្រោងបានទាន់ពេលវេលា
- មន្ត្រីដែលទទួលការងារសិក្សាគម្រោងជាមន្ត្រីថ្មីនៅមិនទាន់មានបទពិសោធន៍សិក្សាគម្រោងនៅឡើយ
- មានឧបករណ៍ និងសម្ភារសម្រាប់ចុះសិក្សាគម្រោងមានសភាពចាស់ៗ ខ្លះខូចប្រើមិនកើតទាំងស្រុង
- ទីចាត់ការផែនការ និងវិនិយោគមិនមានកញ្ចប់ថវិកាជាមធ្យោបាយសម្រាប់មន្ត្រីក្នុងទីចាត់ការ និងមន្ត្រីរបស់មន្ទីរពាក់ព័ន្ធប្រើប្រាស់ចុះសិក្សាគម្រោង
- ការសិក្សាដីធ្លីមានភាពយឺតយូរក្នុងការបញ្ចប់របាយការណ៍ដោយសារតែពិបាកអញ្ជើញប្រជាពលរដ្ឋជាម្ចាស់ក្បាលដីនីមួយៗចូលរួមប្រជុំនិងផ្តិតមេដៃព្រមព្រៀង និងមានម្ចាស់ក្បាលដីខ្លះមានទីលំនៅឆ្ងាយពីខេត្ត

- មន្ត្រីទទួលបន្ទុកគាំទ្រគម្រោងដែលទើបចូលបម្រើការងារថ្មីនៅមិនទាន់យល់ដឹងច្បាស់អំពីគោលការណ៍ណែនាំអនុវត្តន៍គម្រោងក្នុងសៀវភៅកីមនៅឡើយ
- មានការអូសបន្លាយពេលវេលាសិក្សាគម្រោង ដោយសារឃុំ សង្កាត់ទាំងអស់មានកាតព្វកិច្ចរៀបចំការបោះឆ្នោតសកលហើយមិនបានចូលរួមជិតដល់ក្នុងការសិក្សាគម្រោង
- មានមន្ត្រីផ្នែកបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់នៅក្នុងទីចាត់ការផែនការ និង វិនិយោគខេត្ត ដែលមានតួនាទីចុះសិក្សាគម្រោងរួមគ្នាជាមួយមន្ត្រីទទួលបន្ទុកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និង ជនជាតិដើមភាគតិចរបស់ខេត្ត។

ដើម្បីឆ្លើយតបទៅនិងបញ្ហាដែលមានខាងលើ ក្រុមការងារ ប.ជ.ជ. នៃលេខាធិការដ្ឋាន គ.ជ.អ.ប. បានផ្តល់អនុសាសន៍ដូចខាងក្រោម៖

- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ត្រូវបង្កើនកិច្ចសហការគ្នាចុះតាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោងឱ្យបានជិតដល់
- មន្ត្រីគាំទ្រគម្រោងដែលទទួលខុសត្រូវនៅក្នុងឃុំសង្កាត់របស់ខ្លួន ត្រូវខិតខំស្វែងយល់ពីការសិក្សាសុវត្ថិភាពគម្រោងឱ្យស្ទាត់ជំនាញសម្រាប់ជួយគាំទ្រគម្រោង ក្នុងនេះលេខាធិការដ្ឋាន គ.ជ.អ.ប. គួរមានវគ្គរំលឹកឡើងវិញដល់ថ្នាក់ក្រោមជាតិស្តីពីសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ហើយខេត្តគួរផ្តល់លទ្ធភាពដល់មន្ត្រីថ្មីបានចូលរួមក្នុងវគ្គដើម្បីមានសមត្ថភាពពេញលេញជួយគាំទ្រគម្រោង
- លេខាធិការដ្ឋាន គ.ជ.អ.ប. គួរពិចារណាលទ្ធភាពផ្តល់ឧបករណ៍ សម្ភារ និងមធ្យោបាយគ្រប់គ្រាន់ដល់ទីចាត់ការផែនការ និងវិនិយោគសម្រាប់ចុះគាំទ្រគម្រោង
- ខេត្តគួរមានកញ្ចប់ថវិកាដល់មន្ត្រីទទួលបន្ទុកក្នុងទីចាត់ការផែនការ និងវិនិយោគខេត្ត និងមន្ត្រីរបស់មន្ទីរពាក់ព័ន្ធដែលមានការងារចុះគាំទ្រគម្រោង
- ខេត្តគួរមានការតែងតាំងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីបានចុះសិក្សាគម្រោងរួមគ្នាជាមួយមន្ត្រីទទួលបន្ទុកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

សូមជូនភ្ជាប់មកជាមួយនូវរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១៨ចំនួន០១ច្បាប់ និងតារាងឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី**

យុន ប៊ុនណារ៉ា

ចិវន៍ ភីរ៉េត

03/01/19

(ឧបសម្ព័ន្ធ១). តារាងតាមដានការត្រួតពិនិត្យគម្រោងឃុំ សង្កាត់ដែលអនុវត្តកិច្ចការពារសុវត្ថិភាព (ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨)

| លេខកូដ | ឈ្មោះខេត្ត | #ឃុំ សង្កាត់ | #គម្រោងឆ្នាំ២០១៧ | #គម្រោងសិក្សាសុវត្ថិភាព | | | # គម្រោងក្នុងបញ្ជីឃ្លាំមើល Watch List | | #គម្រោងដែលបានពិនិត្យ | | %ដែលបានពិនិត្យ | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្តទាំង២៤ | | | | បរិស្ថាន | ដីធ្លី | ជនជាតិ | បរិស្ថាន | ជនជាតិ | បរិស្ថាន | ជនជាតិ | បរិស្ថាន | ជនជាតិ | |
| 1 | បន្ទាយមានជ័យ | 65 | 73 | 23 | 0 | 0 | 23 | 0 | 21 | 0 | 91% | 0 | |
| 2 | បាត់ដំបង | 102 | 102 | 47 | 0 | 0 | 47 | 0 | 27 | 0 | 57% | 0 | |
| 3 | កំពង់ចាម | 109 | 112 | 14 | 12 | 0 | 14 | 0 | 14 | 0 | 100% | 0 | |
| 4 | កំពង់ឆ្នាំង | 69 | 62 | 20 | 24 | 0 | 20 | 0 | 16 | 0 | 80% | 0 | |
| 5 | កំពង់ស្ពឺ | 87 | 94 | 23 | 0 | 0 | 23 | 0 | 23 | 0 | 100% | 0 | |
| 6 | កំពង់ធំ | 81 | 64 | 61 | 43 | 0 | 46 | 0 | 31 | 0 | 67% | 0 | |
| 7 | កំពត | 93 | 109 | 76 | 53 | 0 | 76 | 0 | 18 | 0 | 24% | 0 | |
| 8 | កណ្ដាល | 127 | 137 | 14 | 14 | 0 | 5 | 0 | 0 | 0 | 0% | 0 | |
| 9 | កោះកុង | 29 | 33 | 27 | 4 | 0 | 27 | 0 | 12 | 0 | 44% | 0 | |
| 10 | ក្រចេះ | 46 | 62 | 36 | 23 | 13 | 36 | 13 | 32 | 11 | 89% | 85% | |
| 11 | មណ្ឌលគិរី | 21 | 62 | 36 | 23 | 13 | 38 | 13 | 3 | 4 | 8% | 31% | |
| 12 | ព្រះវិហារ | 51 | 61 | 49 | 46 | 7 | 49 | 7 | 41 | 4 | 84% | 57% | |
| 13 | ព្រៃវែង | 116 | 131 | 3 | 11 | 0 | 3 | 0 | 0 | 0 | 0% | 0% | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 14 | ពោធិ៍សាត់ | 49 | 59 | 42 | 16 | 2 | 42 | 2 | 27 | 0 | 64% | 0% | |
| 15 | រតនគិរី | 50 | 50 | 41 | 6 | 16 | 41 | 16 | 19 | 24 | 46% | 150% | |
| 16 | សៀមរាប | 100 | 128 | 80 | 2 | 0 | 80 | 0 | 76 | 0 | 95% | 0 | SRL9 |
| 17 | ព្រះសីហនុ | 27 | 29 | 23 | 4 | 0 | 23 | 0 | 12 | 0 | 52% | 0 | |
| 18 | ស្ទឹងត្រែង | 34 | 42 | 42 | 11 | 7 | 42 | 7 | 19 | 1 | 45% | 0 | |
| 19 | ស្វាយរៀង | 80 | 82 | 2 | 32 | 0 | 2 | 0 | 2 | 0 | 100% | 0 | |
| 20 | តាកែវ | 100 | 109 | 11 | 32 | 0 | 11 | 0 | 11 | 0 | 100% | 0 | |
| 21 | ឧត្តរមានជ័យ | 24 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0% | 0 | |
| 22 | កែប | 5 | 7 | 7 | 5 | 0 | 7 | 0 | 7 | 0 | 100% | 0 | |
| 23 | ប៉ៃលិន | 8 | 8 | 8 | 0 | 0 | 8 | 0 | 8 | 0 | 100% | 0 | |
| 24 | ត្បូងឃ្មុំ | 64 | 68 | 4 | 4 | 1 | 4 | 1 | 2 | 0 | 50% | 0 | |
| | **សរុប** | **1537** | **1684** | **689** | **365** | **59** | **667** | **59** | **421** | **44** | **63%** | **75%** | |

## តារាងតាមដានការអនុវត្តគម្រោងក្រុង ស្រុកដែលតម្រូវការសិក្សាសុវត្ថិភាពឆ្នាំ២០១៨( ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨)

| # | លេខកូដ | ឈ្មោះខេត្ត | ចំនួនក្រុងស្រុក | ចំនួនគម្រោងឆ្នាំ២០១៨ | ចំនួនគម្រោងតម្រូវការសិក្សាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច | | | ចំនួនគម្រោងក្នុងបញ្ជីឃ្លាំមើល | | ចំនួនគម្រោងដែលបានពិនិត្យដោយក្រុមការងារសុវត្ថិភាព | | %ភាគរយដែលបានពិនិត្យរួច | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខេត្តចំនួន១៤ | | | | បរិស្ថាន | ដីធ្លី | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | |
| 1 | 4 | កំពង់ឆ្នាំង | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 2 | 5 | កំពង់ស្ពឺ | 8 | 11 | 5 | 0 | 0 | 5 | 0 | 3 | 0 | 60% | | |
| 3 | 8 | កណ្ដាល | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 4 | 14 | ព្រៃវែង | 13 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 5 | 20 | ស្វាយរៀង | 8 | 14 | 1 | 0 | 0 | 1 | 0 | 0 | 0 | | | |
| 6 | 21 | តាកែវ | 10 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 7 | 15 | ពោធិ៍សាត់ | 6 | 21 | 12 | 4 | 0 | 12 | 0 | 0 | 0 | | | |
| 8 | 2 | បាត់ដំបង | 14 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 9 | 7 | កំពត | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 10 | 9 | កោះកុង | 7 | 10 | 10 | 0 | 0 | 10 | 0 | 6 | 0 | 60% | | |
| 11 | 18 | ព្រះសីហនុ | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 12 | 23 | កែប | 2 | 4 | 3 | 2 | 0 | **3** | 0 | 3 | 0 | 100% | | |
| 13 | 13 | ព្រះវិហារ | 8 | 24 | 16 | 0 | 24 | 16 | 24 | 13 | 1 | 81% | 4% | |
| 14 | 10 | ក្រចេះ | 6 | 6 | 3 | 0 | 1 | 3 | 1 | 0 | 0 | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 15 | 1 | បន្ទាយមានជ័យ | 9 | 30 | 12 | 0 | 0 | 12 | 0 | 12 | 0 | 100% | | |
| 16 | 3 | កំពង់ចាម | 10 | 37 | 5 | 0 | 0 | 5 | 0 | 5 | 0 | 100% | | |
| 17 | 6 | កំពង់ធំ | 8 | 19 | 9 | 1 | 1 | 9 | 1 | | 1 | | 100% | |
| 18 | 11 | មណ្ឌលគិរី | 5 | 13 | 10 | 0 | 13 | 10 | 13 | 10 | 13 | 100% | 100% | |
| 19 | 16 | រតនគិរី | 9 | 23 | 17 | 11 | 14 | 17 | 14 | 4 | 2 | 24% | 14% | |
| 20 | 17 | សៀមរាប | 12 | 43 | 24 | 1 | 0 | 26 | 0 | 26 | 0 | 100% | | |
| 21 | 19 | ស្ទឹងត្រែង | 5 | 10 | 10 | 0 | 0 | 10 | 0 | 10 | 0 | 100% | | |
| 22 | 22 | ឧត្តរមានជ័យ | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 23 | 24 | ប៉ៃលិន | 2 | 6 | 6 | 0 | 0 | 6 | 0 | 3 | 0 | 50% | | |
| 24 | 25 | ត្បូងឃ្មុំ | 7 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| | | **សរុប** | **185** | **271** | **143** | **19** | **53** | **145** | **53** | **95** | **17** | **66%** | **32%** | |

## តារាងតាមដានការអនុវត្តគម្រោងក្រុង ស្រុកដែលតម្រូវការសិក្សាសុវត្ថិភាពឆ្នាំ២០១៨( ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៨)

| # | លេខកូដ | ឈ្មោះខេត្ត | ចំនួនក្រុងស្រុក | ចំនួនគម្រោងឆ្នាំ២០១៨ | ចំនួនគម្រោងតម្រូវការសិក្សាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច | | | ចំនួនគម្រោងក្នុងបញ្ជីឃ្លាំមើល | | ចំនួនគម្រោងដែលបានពិនិត្យដោយក្រុមការងារសុវត្ថិភាព | | %ភាគរយដែលបានពិនិត្យរួច | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខេត្តចំនួន១៤ | | | | បរិស្ថាន | ដីធ្លី | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | បរិស្ថាន | ជនជាតិដើម | |
| 1 | 4 | កំពង់ឆ្នាំង | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 2 | 5 | កំពង់ស្ពឺ | 8 | 11 | 5 | 0 | 0 | 5 | 0 | 3 | 0 | 60% | | |
| 3 | 8 | កណ្ដាល | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 4 | 14 | ព្រៃវែង | 13 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 5 | 20 | ស្វាយរៀង | 8 | 14 | 1 | 0 | 0 | 1 | 0 | **0** | 0 | | | |
| 6 | 21 | តាកែវ | 10 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 7 | 15 | ពោធិ៍សាត់ | 6 | 21 | 12 | 4 | 0 | 12 | 0 | 0 | 0 | | | |
| 8 | 2 | បាត់ដំបង | 14 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 9 | 7 | កំពត | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 10 | 9 | កោះកុង | 7 | 10 | 10 | 0 | 0 | 10 | 0 | 6 | 0 | 60% | | |
| 11 | 18 | ព្រះសីហនុ | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 12 | 23 | កែប | 2 | 4 | 3 | 2 | 0 | 3 | 0 | 3 | 0 | 100 % | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 13 | 13 | ព្រះវិហារ | 8 | 24 | 16 | 0 | 24 | 16 | 24 | 13 | 1 | 81% | 4% | |
| 14 | 10 | ក្រចេះ | 6 | 6 | 3 | 0 | 1 | 3 | 1 | 0 | 0 | | | |
| 15 | 1 | បន្ទាយមានជ័យ | 9 | 30 | 12 | 0 | 0 | 12 | 0 | 12 | 0 | 100 % | | |
| 16 | 3 | កំពង់ចាម | 10 | 37 | 5 | 0 | 0 | 5 | 0 | 5 | 0 | 100 % | | |
| 17 | 6 | កំពង់ធំ | 8 | 19 | 9 | 1 | 1 | 9 | 1 | | 1 | 0% | 100% | |
| 18 | 11 | មណ្ឌលគិរី | 5 | 13 | 10 | 0 | 13 | 10 | 13 | 10 | 13 | 100 % | 100% | |
| 19 | 16 | រតនគិរី | 9 | 23 | 17 | 11 | 14 | 17 | 14 | 4 | 2 | 24% | 14% | |
| 20 | 17 | សៀមរាប | 12 | 43 | 24 | 1 | 0 | 26 | 0 | 26 | 0 | 100 % | | |
| 21 | 19 | ស្ទឹងត្រែង | 5 | 10 | 10 | 0 | 0 | 10 | 0 | 10 | 0 | 100 % | | |
| 22 | 22 | ឧត្តរមានជ័យ | 5 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | | | |
| 23 | 24 | ប៉ៃលិន | 2 | 6 | 6 | 0 | 0 | 6 | 0 | 3 | 0 | 50% | | |
| 24 | 25 | ត្បូងឃ្មុំ | 7 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0% | | |
| | | **សរុប** | **185** | **271** | **143** | **19** | **53** | **145** | **53** | **95** | **17** | **66%** | **32%** | |

## (ឧបសម្ព័ន្ធ ២)៖ បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្តឆ្នាំ២០១៨

| ល.រ | ឈ្មោះ | ភេទ | ស្ថាប័ន ឬ អង្គភាព និង តួនាទី | តួនាទី | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|---|
| I | **ខេត្តកំពង់ចាម** | | | | | |
| 1 | អ៊ុំ ប៉ុណ្ណកា | ប | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 887040 | <om.ponnaka@kpc.ncdd.gov.kh> |
| 2 | តុល កាណាល់ | ប | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | អនុប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 017 570 202 | <kanal_tol@yahoo.com> |
| 3 | ងី សុខចេង | ស | មន្ត្រីទីចាត់ការផែនការនិងវិនិយោគខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 575 171 | <sokchengngy@gmailçom> |
| II | **ខេត្តក្រចេះ** | | | | | |
| 4 | ប៉ែន រដ្ឋា | ប | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 378 977 | <rotha@krt.ncdd.gov.kh> |
| 5 | អ៊ឹម ណូរ៉ា | ប | អនុប្រធានការិយាល័យវិនិយោគខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 55 87 82 | <im_nora@yahoo.com> |
| 6 | ភាន សុភ:មី | ប | ប្រធានការិយាល័យ រដ្ឋបាលមន្ទីរបរិស្ថានខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 088 940 7373 | NA |
| III | **ខេត្តមណ្ឌលគិរី** | | | | | |
| 7 | កុយ រតនា | ប | នាយកទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 011 272 093 | <ratnakoy@gmailcom> |
| 8 | ឆាយា សុខ័យ្យា | ស | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | អនុប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 011 668 788 | <Sokhaya_yaya88@yahoo.com> |
| 9 | ជឹម រតនៈ | ប | អនុប្រធានការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 076 666 6791 | <rothanakchimmkr@gmail.com> |
| IV | **ខេត្តរតនគិរី** | | | | | |
| 10 | ឡេង ភា | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 098 387 007 077 247 107 | < lengphea7th@yahoo.com> |
| 11 | ហោ ភិរិន | ស | នាយករងទីចាត់ការផែនការ | ជនបង្គោលកិច្ចការពារសុវត្ថិ | 012 278 256 | <narinncdd@gmail.com> |

| | | | | | | |
|---|---|---|---|---|---|---|
| | | | និងវិនិយោគខេត្ត | ភាព | | |
| 12 | ញ៉ ផានិត | ប | មន្ត្រីការិយាល័យគាំទ្រមូលដ្ឋាន | ជនបង្គោលកិច្ចការពារសុវត្ថិភាព | 975353625 | <phanitrat16@gmail.com> |
| V | **ខេត្តស្ទឹងត្រែង** | | | | | |
| 13 | សៀ ហេង | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 088 77777 68 | <searheng777@yahoo.com> |
| 14 | កែវ សំអុល | ប | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 75 53 399 | NA |
| 15 | មី សុភា | ប | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 017 928 002 | <m.sophea.stg@gmail.co> |
| VI | **ខេត្តព្រះវិហារ** | | | | | |
| 16 | គុជ សុវណ្ណារី | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 960 139 | <kuch.sovannary@gmail.com> |
| 17 | ស៊ុម សេត | ប | នាយករងទីចាត់ការផែនការនិងវិនិយោគខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 717 5773 | <sum.seth@hotmail.com> |
| 18 | កែវ លីន | ប | អនុប្រធានការិយាល័យផែនការ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 214 4481 | <linkeo.pvr@gmail.com> |
| VII | **ខេត្តកំពង់ធំ** | | | | | |
| 19 | លី វ៉េត | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 017 291 890 | <Ly.vet@kpt.ncdd.gov.kh>; <vetly18@yahoo.com> |
| 20 | អោង ប៊ុនធឿន | ប | អនុប្រធានមន្ទីរបរិស្ថានខេត្ត | អនុប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 583 467 | NA |
| 21 | ស៊ុន រដ្ឋេ | ប | អនុប្រធានការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 078 714 005 | <sun.rathe@kpt.ncdd.gov.kh> |
| VIII | **ខេត្តសៀមរាប** | | | | | |
| 22 | ទិព្វ ពិសិទ្ធិ | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 017 665 954 | <tippiseth@gmail.com> |
| 23 | ថាន់ មនោមយិទ្ធិ | ប | មន្ត្រីមន្ទីរបរិស្ថានខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិ | 017 509 558 | <monoyith@yahoo.com> |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ភាព | | |
| 24 | ប៊ិន វេជ្ជ | ប | មន្ត្រីទីចាត់ការផែនការនិងវិនិយោគខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 867 4776 | <srppid@yahoo.com> |
| IX | **ខេត្តបន្ទាយមានជ័យ** | | | | | |
| 25 | ហាយ សំណាង | ប | នាយកទីចាត់ការផែនការ និងវិនិយោគ | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 788 785 / 092 657 487 | <hay.samnang@yahoo.com> |
| 26 | អ៊ុំ សម្បត្តិ | ប | ប្រធានការិយាល័យផែនការ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 596 107 | NA |
| 27 | យ៉ោក យឿម | ប | មន្ត្រីមន្ទីរបរិស្ថាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 017 330 207 | NA |
| X | **ខេត្តឧត្តរមានជ័យ** | | | | | |
| 28 | ឃិត សាម៉ាក់ | ប | នាយកទីចាត់ការផែនការ និងវិនិយោគ | ប្រធានក្រុមជនបង្គោលកិច្ចការពារសុវត្ថិភាព | 012 449 672 | <samak.khit@gmail.com> |
| 29 | ចាប ឧត្តម | ប | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 88 21008 | <oddam88nrm@gmail.com> |
| 30 | អាន គង្គា | ប | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 066 365 606 | <kung_kea@yahoo.com> |
| XI | **ខេត្តប៉ៃលិន** | | | | | |
| | យ៉ាន អ៊ិត | ប | នាយកទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 015 375 454 | <Yanith168@gmail.com> |
| 31 | ស៊ុន ម៉េងឃី | ប | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 7283608 | <son.mengkhy@pln.ncdd.gov.kh> |
| 32 | ង៉ែត សុខេម | ប | អនុប្រធានការិយាល័យផែនការ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 728 3608 | <nget.sokkem555@gmail.com> |
| 33 | អ៊ិន ចាន់ណា | ប | មន្ត្រីការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព (ថ្មី ) | 070 341617 | <channabtb1617@gmail.com> |
| XII | **ខេត្តកំពង់ឆ្នាំង** | | | | | |
| 34 | ហង់ ពិសី | ប | នាយកទីចាត់ការផែនការនិង | ប្រធានក្រុមជនបង្គោលកិច្ច | NA | <hangpisey@yahoo.com> |

| | | | | | | |
|---|---|---|---|---|---|---|
| | | | វិនិយោគខេត្ត | ការពារសុវត្ថិភាព | | |
| 35 | អ៊ុក ណុច | ប | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានជនបង្គោលកិច្ចការពារសុវត្ថិភាព | 017 867 373 | N/A |
| 36 | ឡេង សំអិត | ប | អនុប្រធានមន្ទីរបរិស្ថានខេត្ត | អនុប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 657 464 | <leng_sameth@yahoo.com> |
| XIII | **ខេត្តកំពង់ស្ពឺ** | | | | | |
| 37 | ចិន សាម៉េត | ប | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 016 661 546 | <samethksp@yahoo.com> |
| 38 | សួស សុផល | ប | អនុប្រធានមន្ទីរបរិស្ថានខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 362 825 | N/A |
| 39 | ជុំ ចំរើន | ប | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 092 923 745 | <chumchamreun2008@gmail.com> |
| XIV | **ខេត្តកណ្តាល** | | | | | |
| 40 | រស់ សុទ្ធា | ប | នាយកទីចាត់ការផែនការនិងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 623 923 | <rous.sothea@vmail.com> |
| 41 | វ៉ាន់ សុផល | ប | នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 017 397 426 | N/A |
| 42 | ស៊ុម សារិត | ប | អនុប្រធានមន្ទីរបរិស្ថានខេត្ត | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 237 504 | N/A |
| XV | **ខេត្តព្រៃវែង** | | | | | |
| 43 | សុខ មករា | ប | អនុការិយាល័យ បច្ចេកទេសគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 077 614 619 | N/A |
| 44 | ហេង សាងហ៊ី | ប | ប្រធានការិ. ការពារ និងអភិរក្សធនធានធម្មជាតិ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 090 666 411 | <hengseinghymvu@gmail.com> |
| 45 | សុខ សារុន | ប | មន្ត្រីបច្ចេកទេស គាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 973 3714 | <soksarun168@gmail.com> |
| XVI | **ខេត្តស្វាយរៀង** | | | | | |
| 46 | អេង សុវណ្ណ | ប | នាយកទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | | |

| | | | | | | |
|---|---|---|---|---|---|---|
| 47 | ប្រាក់ ដារ៉ា | ប | អនុប្រធានការិ.គាំទ្រមូលដ្ឋាន | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 979777868 | <prakdara097@gmail.com> |
| XVII | **ខេត្តតាកែវ** | | | | | |
| 48 | ហេង វុទ្ធី | ប | នាយកទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 077 883 031 | <hengvuthy2012@gmail.com> |
| 49 | ជា ថាច | ប | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន(ដីធ្លី) | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 011760 552 | <cheathach@tak.ncdd.gov.kh> |
| 50 | ពង្ស វិរៈ | ប | ប្រធានការិយាល័យគាំទ្រគម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 818706 | <vireak_pong@yahoo.com> |
| XVIII | **ខេត្តពោធិ៍សាត់** | | | | | |
| 51 | ធឹង ស្រីពេជ្រ | ស | នាយករងទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 089 909 775 | <sreypechchhoeung@yahoo.com>; |
| 52 | ដាង រ៉ាឌី | ប | អនុប្រធានការិយាល័យផែនការច្បាប់បរិស្ថាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | N/A | N/A |
| 52 | ពេជ្រ សុវណ្ណ | ប | ប្រធានការិយាល័យ ផែនការ | ប្រធានក្រុមជនបង្គោលកិច្ចការពារសុវត្ថិភាព | 092 520 010 | <p.sovann@pur.ncdd.gov.kh> |
| 53 | ជឹង វឌ្ឍនៈ | ប | មន្ត្រីការិយាល័យ គាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | N/A | <vathanak.choeng@gmail.com> |
| XVIV | **ខេត្តបាត់ដំបង** | | | | | |
| 54 | ហាន ស៊ីហ៊ីប | ប | នាយកទីចាត់ការផែនការ និង វិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 017 766 636 | <hansihip@yahoo.com> |
| 55 | ជួ សាន | ប | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 752 357 | <chuosan@yahoo.com> |
| 56 | រឿម ផល្លី | ប | មន្ត្រីការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 092 901 545 | N/A |
| 57 | កៅ ជន | ប | អនុប្រធានមន្ទីរបរិស្ថាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 580 494 | N/A |
| XX | **ខេត្តកំពត** | | | | | |
| 58 | ស៊ុន កាក់សាន្ត | ប | នាយករងទីចាត់ការផែនការ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិ | 017 818 130 | <kaksann.sun@gmail.com> |

| | | | | | | |
|---|---|---|---|---|---|---|
| | | | និងវិនិយោគខេត្ត | ភាព | | |
| 59 | វ៉ែន សុភ័ណ្ឌ | ប | ប្រធានការិយាល័យគាំទ្រ គម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 092 405 016 | <sophorn.ven@gmail.com> |
| 60 | ឈាង សុខឡេង | ស | មន្ត្រីទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 016 851 370 | |
| XXI | **ខេត្តកោះកុង** | | | | | |
| 61 | សេក សំអុល | ប | នាយកទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 016 863 939 | <seksamol2011@gmail.com> |
| 62 | ហេង ចាន់ថន | ប | នាយករងទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 34 30 45,<br>015 21 45 12 | <hengchanthan@yahoo.com> |
| 63 | ដៃ ចិន្តា | ប | អនុការិយាល័យរដ្ឋបាលមន្ទីរបរិស្ថាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 016 555 603 | NA |
| 64 | វ៉ែន សុខា | ប | មន្ត្រីការិយាល័យគាំទ្រគម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | NA | < ven.sokha@yahoo.com> |
| XXII | **ខេត្តព្រះសីហនុ** | | | | | |
| 65 | ចេន រ៉េត | ប | នាយកទីចាត់ការផែនការ និង វិនិយោគ | ប្រធានក្រុមជនបង្គោលកិច្ចការពារសុវត្ថិភាព | 015 737 756 | <reth@ncdd.gov.kh> |
| 66 | ឈួក មាន | ប | មន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 722 4447 | <mean@shv.ncdd.gov.kh> |
| 67 | អេង ចំរើន | ប | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 745 4573 | <maosokheng123@gmail.com> |
| XXIII | **ខេត្តកែប** | | | | | |
| 68 | សួន ភាព | ប | នាយកទីចាត់ការផែនការ និង វិនិយោគ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 235 4000 | <soun.pheap@kep.ncdd.gov.kh> |
| 69 | ជា ដារិទ្ធ | ប | មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 235 4000 | <chadarith.kep@gmail.com> |
| 70 | យន់ ខេង | ប | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 226 427 | <Kheng_yon@yahoo.com> |

| | | | | | | |
|---|---|---|---|---|---|---|
| 71 | គួច លាង | ស | ប្រធានការិយាល័យបរិស្ថានស្រុក | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | NA | NA |
| XXIV | **ខេត្តត្បូងឃ្មុំ** | | | | | |
| 72 | វ៉ា គីមហេង | ប | នាយកទីចាត់ការផែនការ និងវិនិយោគខេត្ត | ប្រធានក្រុមការងារកិច្ចការពារសុវត្ថិភាព | 012 499 463 | <Kimhenh.va@gmail.com> |
| 73 | គុន ស៊ុនលី | ប | ប្រធានការិយាល័យគាំទ្រគម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 097 665 0222 | <kunsunly168@gmail.com> |
| 74 | ហឺង ស្រី | ប | អនុប្រធានការិយាល័យគាំទ្រគម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 071 993 3332 | <heunsrey2011@gmail.com> |
| 75 | ភី សួស្តី | ប | អនុប្រធានការិយាល័យគាំទ្រគម្រោង | មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាព | 012 809 707 | <phy.soursdey@gmail.com> |

**សរុបចំនួន ៧៥នាក់ ស្ត្រី៦នាក់**